

# ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ៖
## ការបាត់បង់ដីធ្លី និងការរំលោភបំពានក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

របាយការណ៍

ចេញផ្សាយ ខែសីហា ឆ្នាំ២០១៩

# ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ៖

## ការបាត់បង់ដីធ្លី និងការរំលោភបំពានក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

របាយការណ៍ចេញផ្សាយ ខែសីហា ឆ្នាំ២០១៩


សមាគមធាងត្នោត
Sahmakum Teang Tnaut • a Cambodian Urban NGO

សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើត ឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និង លើកកម្ពស់ ការគោរពសិទ្ធិទាំងនេះ ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវ សមិទ្ធិផលល្អក្នុងអតីតកាល លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលស្ថានភាពសង្គមតាមរយៈកម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស ពីការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងនៅតាមសាខាទាំង ១៣ ខេត្តផ្សេងទៀត។

ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ ធ្វើការឃ្លាំមើលលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយអាជ្ញាធរ ការរំលោភបំពានលើស្ត្រី និងកុមារ។ ជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈ ការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។ ការិយាល័យឃ្លាំមើលពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន ១៨កន្លែង ដើម្បីវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថា ជនជាប់ឃុំទទួលបាននូវការតំណាងផ្នែកច្បាប់។ ការិយាល័យច្បាប់ផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ និងផ្តល់ជូនមេធាវីសិទ្ធិមនុស្ស សម្រាប់ជាតំណាងផ្លូវច្បាប់ លើករណីសំខាន់ៗមួយចំនួន។ ការិយាល័យ លើកកម្ពស់សិទ្ធិ និងទាក់ទាញមតិគាំទ្រ ចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារ: (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែល: contact@licadho-cambodia.org
គេហទំព័រ: www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# សមាគមធាងត្នោត

សមាគមធាងត្នោត (STT) ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៥ និងត្រូវបានចុះបញ្ជីជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជួយគាំទ្រដល់សហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ នៅឆ្នាំ២០០៦។ សមាគមធាងត្នោត ចាប់ផ្តើមជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកតូចមួយ ដែលផ្តោតទៅលើការជួយលើកកម្ពស់ផ្នែកបច្ចេកទេសដល់សហគមន៍ក្រីក្រ និង បន្ទាប់មកចាប់ផ្តើមរីកលូតលាស់ខ្លួន ដោយធ្វើការបង្កើតជាផែនទីសហគមន៍ក្រីក្រ ការសិក្សាស្រាវជ្រាវ និងការតស៊ូមតិ ដើម្បីសម្រេចគោលដៅរបស់ខ្លួនក្នុងការជួយដល់សហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ ឱ្យទទួលបាននូវសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោក សឿង សារ៉ន, នាយកប្រតិបត្តិនៃសមាគម ធាងត្នោត
រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទលេខ៖ (+៨៥៥) ៨៩ ៦៦៦ ០១៣
អ៊ីម៉ែល៖: director@teangtnaut.org
Web: www.teangtnaut.org Facebook: https://www.facebook.com/teangtnaut Twitter: https://twitter.com/teangtnaut

# មាតិកា


ខ្លឹមសារសង្ខេប — ទំព័រទី ១

សាវតា — ទំព័រទី ៤

វិធីសាស្ត្រ — ទំព័រទី ៦

ការរកឃើញនៃការសិក្សា — ទំព័រទី ៧

- ការអនុវត្តផ្តល់ប្រាក់កម្ចីគ្មានក្រមសីលធម៌ — ទំព័រទី ៧
- ការលក់ដីដោយបង្ខំ — ទំព័រទី ៨
- ការបាត់បង់ទីលំនៅ — ទំព័រទី ១១
- ពលកម្មកុមារ — ទំព័រទី ១២
- ការចំណាកស្រុក — ទំព័រទី ១៣
- ការបញ្ចាំខ្លួនដោះបំណុល — ទំព័រទី ១៥
- អ្នកចងការប្រាក់ឯកជន — ទំព័រទី ១៦

បទបញ្ញត្តិ និងការការពារអ្នកប្រើប្រាស់ឥណទាន — ទំព័រទី ១៧

អនុសាសន៍ — ទំព័រទី ២០

ភាពជាម្ចាស់កម្មសិទ្ធិ — ទំព័រទី ២១


*ការស្រាវជ្រាវនេះ គឺមិនត្រូវបានធ្វើឡើងក្នុងគោលបំណងតំណាងឱ្យតួលេខទាំងអស់នៅក្នុងប្រទេសកម្ពុជា ឬការរកឃើញពីអតិថិជនទាំងអស់នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជានោះទេ។ របាយការណ៍នេះ គ្រាន់តែត្រូវបានធ្វើឡើង ដើម្បីបង្ហាញអំពីបញ្ហាមួយចំនួនដែលអ្នកស្រាវជ្រាវបានរកឃើញនៅតាមតំបន់គោលដៅ ដូចជាការបាត់បង់ដីធ្លី ជាដើម ដែលធ្វើឱ្យស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាកាន់តែធ្លាក់ចុះ និងធ្វើឱ្យភាពក្រីក្រនៅកម្ពុជាកាន់តែកើនឡើង។ ការស្រាវជ្រាវបន្ថែមទៀតទៅថ្ងៃខាងមុខ គួរត្រូវបានពិចារណាដោយវាមានសារៈសំខាន់ ដើម្បីកំណត់ពីទំហំពិតប្រាកដ និងកម្រិតនៃភាពធ្ងន់ធ្ងរនៃបញ្ហាទាំងនោះដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍នេះ។*

*របាយការណ៍នេះ គឺជារបាយការណ៍ដំបូងនៃរបាយការណ៍មួយចំនួនទៀតរបស់អង្គការ លីកាដូ អំពីឥណទានខ្នាតតូចនៅកម្ពុជា។*

# ខ្លឹមសារសង្ខេប

បំណុលមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ដែលភាគច្រើនតម្រូវឱ្យដាក់បញ្ចាំ នូវប័ណ្ណកម្មសិទ្ធិដីធ្លី បានបង្កជា ការគំរាមកំហែងដល់សុវត្ថិភាព នៃសិទ្ធិកាន់កាប់ដីធ្លី របស់គ្រួសារជំពាក់បំណុល និងបានបង្កឱ្យមានការរំលោភបំពាន ជាលក្ខណៈជាប្រព័ន្ធយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។ ខណៈដែលកំពុងរៀបចំរបាយការណ៍នេះ ក្រុមអ្នកស្រាវជ្រាវ បានរកឃើញករណីជាច្រើន អំពីការឃាយី របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទៅលើអ្នកខ្ចីប្រាក់ ដើម្បីឱ្យពួកគេសងប្រាក់កម្ចីវិញ។ បទសម្ភាសន៍ជាមួយអតិថិជន និងថ្នាក់ដឹកនាំ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានចោទជាសំណួរ ថាតើអនុបាតទាប នៃចំនួនឥណទានមិនដំណើរការ[1] របស់វិស័យមីក្រូហិរញ្ញវត្ថុ អាចកើតមាន គឺដោយសារតែការលក់ដីធ្លីដោយបង្ខំ ការប្រើប្រាស់ពលកម្មកុមារ ការធ្វើចំណាកស្រុកព្រោះតែបំណុល កង្វះខាតស្បៀងអាហារ និងការរំលោភបំពានលើសិទ្ធិមនុស្សដទៃផ្សេងទៀត ឬយ៉ាងណា? គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដំបូងឡើយ គឺចាប់ផ្តើមជាគម្រោងកាត់បន្ថយភាពក្រីក្រតាមរយៈការផ្តល់ប្រាក់កម្ចី ឱ្យទៅប្រជាពលរដ្ឋ ដែលមិនមានលទ្ធភាពទទួលបានឥណទាន ឬ ប្រាក់កម្ចីពីធនាគារ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅតែរក្សាកេរ្តិ៍ឈ្មោះបានល្អ ក្នុងចំណោមដៃគូអភិវឌ្ឍន៍រហូតមក។ មីក្រូហិរញ្ញវត្ថុធំៗភាគច្រើននៅក្នុងប្រទេសកម្ពុជា ទទួលបានការគាំទ្រពី ឬ កាន់កាប់ដោយធនាគារបរទេស ក្រុមហ៊ុនវិនិយោគទុន និង ភ្នាក់ងារអភិវឌ្ឍន៍លោកខាងលិច។ ប៉ុន្តែមីក្រូហិរញ្ញវត្ថុទាំងនេះ បានផ្អែកទៅលើភាពខ្វះចន្លោះយ៉ាងទូលំទូលាយនៃបទបញ្ញត្តិរាជរដ្ឋាភិបាល និង ភាពស្មុគស្មាញនៃអាជ្ញាធរមូលដ្ឋាន ដើម្បីជម្រុញ និងដាក់សម្ពាធ ឱ្យអ្នកខ្ចីប្រាក់លក់ដីធ្លីដោយបង្ខំ ហើយទាញយកបានប្រាក់ចំណេញ រាប់រយលានដុល្លារ ពីគ្រួសារក្រីក្រកម្ពុជាជាច្រើន។

នាដើមឆ្នាំ២០១៩ ប្រជាពលរដ្ឋកម្ពុជា ប្រមាណ ២,៤ លាន នាក់បានជំពាក់បំណុលយ៉ាងតិចសរុប ៨ពាន់ លានដុល្លារ[2] ជាចំនួនទឹកប្រាក់ដែលស្មើនឹងមួយភាគបី នៃផលិតផលក្នុងស្រុកសរុប[3]។ បំណុលមីក្រូហិរញ្ញវត្ថុគិតក្នុងម្នាក់ ជាមធ្យមនៅក្នុងប្រទេសកម្ពុជា មានចំនួនប្រមាណ ៣,៣៧០ ដុល្លារ ដែលជាចំនួនមធ្យមខ្ពស់ជាងគេក្នុងពិភពលោក[4]។ តួលេខនេះ ស្ទើរស្មើនឹងតួលេខកណ្តាលនៃប្រាក់ចំណូល ក្រោយកាត់ពន្ធសម្រាប់គ្រួសារ ជនបទទាំងអស់នៅកម្ពុជាក្នុងឆ្នាំ ២០១៧ (ប្រមាណ ៣,៩០០ដុល្លារ) និង លើសទ្វេដងនៃផលិតផលក្នុងស្រុកសរុប សម្រាប់មនុស្សម្នាក់ ក្នុងឆ្នាំ ២០១៧ (១,៤២៧ដុល្លារ)[5]។ ការប៉ាន់ស្មានចំនួន ៨ពាន់ លានដុល្លារនេះ គឺជាការវាយតម្លៃតួលេខទាបមួយ សម្រាប់វិស័យមីក្រូឥណទាននៅកម្ពុជា ដោយផ្អែកលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ធនាគារពាណិជ្ជចំនួនពីរទៀតតែប៉ុណ្ណោះ ដែលបានផ្តល់មីក្រូឥណទាន។ ការផ្តល់ប្រាក់កម្ចីមិនផ្លូវការ ជាទូទៅមិនមានការកត់ត្រា និងសិក្សាស្រាវជ្រាវឡើយ ដែលជាហេតុធ្វើឱ្យមានភាពលំបាក ក្នុងការវាយតម្លៃឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ អំពីឥណទានខ្នាតតូច នៅក្នុងប្រទេសកម្ពុជា។

អំឡុងពេលចុះធ្វើកម្មសិក្សាស្រាវជ្រាវ រយៈពេលបីសប្តាហ៍ ក្រុមអ្នកស្រាវជ្រាវ បានសម្ភាសពលរដ្ឋចំនួន ២៨ គ្រួសារ ដែលមានសមាជិកគ្រួសាររងគ្រោះ ពីអំពើរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ និង/ឬជាច្រើនដង ដោយសារតែ ជំពាក់បំណុលរបស់មីក្រូហិរញ្ញវត្ថុ។ ក្នុងចំណោម ២៨គ្រួសារនេះ មានគ្រួសារចំនួន ២២ ត្រូវបានគេបង្ខំឱ្យលក់ដីធ្លី។ ប្រជាពលរដ្ឋចំនួន ១៣គ្រួសារ ពាក់ព័ន្ធទៅនឹង ការប្រើប្រាស់ពលកម្មកុមារ។ គ្រួសារចំនួន ១៨ មានសមាជិកធ្វើចំណាកស្រុកព្រោះតែបំណុល ។ គ្រួសារចំនួន ២៦ បរិភោគអាហារមានគុណភាពអន់ ឬបរិមាណតិចជាងមុនដើម្បី សន្សំប្រាក់សងបំណុល។ លើសពីនេះ គ្រួសារចំនួន២០ យកកម្ចីយ៉ាងតិចមួយផ្សេងទៀត ដើម្បីយកទៅសងប្រាក់កម្ចីរបស់មីក្រូហិរញ្ញវត្ថុ។ គ្រួសារចំនួន ២២ បានខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជន ខណៈដែលកំពុងជំពាក់ប្រាក់មីក្រូហិរញ្ញវត្ថុ។ នេះបង្ហាញឱ្យឃើញថាកម្ចីផ្លូវការពីមីក្រូហិរញ្ញវត្ថុ និងកម្ចីឯកជនមិនផ្លូវការកើតឡើងបន្តគ្នា បង្កើតជាវដ្តមួយ ដែលធ្វើឱ្យអ្នកខ្ចីជំពាក់បំណុលកាន់តែច្រើន។

បញ្ហាទូទៅមួយទៀតដែលអ្នកស្រាវជ្រាវបានសង្កេតឃើញ គឺការផ្តល់ប្រាក់កម្ចី ដោយមិនយកចិត្តទុកដាក់ របស់មន្ត្រីឥណទានរបស់មីក្រូហិរញ្ញវត្ថុជាច្រើន រួមមានទាំងការឱ្យកម្ចីទៅអតិថិជនដែលមិនមានលទ្ធភាពសងវិញ និងការដាក់សម្ពាធដល់អតិថិជនឱ្យសងប្រាក់

[1] ឥណទានមិនដំណើរការ គឺជាឥណទានដែលអ្នកខ្ចីមិនបានទូទាត់សងក្នុងរយៈពេលលើសពី៣០ថ្ងៃក្រោយពេលកំណត់។

[2] គិតរួមបញ្ចូលទាំងតុល្យភាព ឥណទានខ្នាតតូច របស់ធនាគារអេស៊ីលីដា និងធនាគារស្ថាបនា។

[3] មិនមាននិយមន័យជាក់លាក់សម្រាប់មីក្រូឥណទាននៅកម្ពុជា។ របាយការណ៍នេះប្រើប្រាស់និយមន័យថាជាឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬ ឥណទានខ្នាតតូច របស់ធនាគារពាណិជ្ជ។

[4] របាយការណ៍ប៉ារ៉ូម៉ែតមីក្រូហិរញ្ញវត្ថុឆ្នាំ ២០១៨ ការរួមគ្នា ទំព័រទី២ ប្រទេសប៉េរូជាប់ចំណាត់ថ្នាក់ទីពីរដែលមានចំនួនមធ្យមស្មើនឹង ២,៤៧១ដុល្លារ។

[5] អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៧ វិទ្យាស្ថានជាតិស្ថិតិ ទំព័រទី៧៦ មាននៅ https://www.nis.gov.kh/nis/CSES/Final%20Report%20CSES%202017.pdf

តាមរយៈការបង្ខំឱ្យលក់ដីធ្លី ឬតាមរយៈវិធានការគ្មានក្រមសីលធម៌ផ្សេងទៀត។ គ្រួសារដែលត្រូវបានសម្ភាសទាំងអស់នេះ បានរៀបរាប់ប្រាប់ថា ពួកគាត់បានធ្លាក់ក្នុងសភាពកាន់តែលំបាកជាងមុន ក្រោយពេលពួកគាត់ខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

កំណើនកម្ចីមីក្រូហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា បានកើនលើសកំណើនប្រាក់ចំណូល ប៉ុន្តែប្រជាពលរដ្ឋកម្ពុជាទូទៅ នៅតែអាចបន្តសងកម្ចីរបស់ពួកគេបានយ៉ាងទៀងទាត់។ អនុបាតឥណទានមិនដំណើរការ ឬភាគរយនៃកម្ចី ដែលអ្នកខ្ចីមិនបានបង់សង លើសពី៣០ថ្ងៃឡើងទៅ ក្រោយពេលកំណត់ គឺមាន ១,៨% សម្រាប់មីក្រូឥណទាននាចុងឆ្នាំ២០១៨ ដែលជាសញ្ញាបង្ហាញថាវិស័យឥណទានមានភាពល្អប្រសើរ។ ទោះជាយ៉ាងនេះក្តី ការរកឃើញ នៃការសិក្សាស្រាវជ្រាវនេះបានឱ្យដឹងថា តួលេខនេះ ទាបមួយផ្នែក គឺដោយសារតែប្រជាពលរដ្ឋកម្ពុជាលក់ដីធ្លី ទាំងដីស្រែចំការ និងផ្ទះសម្បែង និងខ្ចីប្រាក់បន្ថែម ដើម្បីយកទៅសងមីក្រូឥណទាន របស់ពួកគេ។ ការលក់ដីធ្លីនេះកើតឡើង ជាញឹកញាប់ បន្ទាប់ពីទទួលរងសម្ពាធពី មីក្រូហិរញ្ញវត្ថុ ឬអាជ្ញាធរមូលដ្ឋាន។ ដីភាគច្រើន ត្រូវបានដាក់តម្កល់ ជាការធានាសម្រាប់កម្ចីពីមីក្រូហិរញ្ញវត្ថុ ហើយមន្ត្រីមីក្រូហិរញ្ញវត្ថុ នឹងទទូចឱ្យអតិថិជនលក់ដីធ្លីនោះ ដើម្បីសងប្រាក់កម្ចីរបស់ពួកគេ។ អតិថិជនរបស់មីក្រូហិរញ្ញវត្ថុ ដែលក្រុមអ្នកស្រាវជ្រាវ បានសម្ភាស ភាគច្រើន ទទួលរងនូវអំពើរំលោភបំពានសិទ្ធិមនុស្ស ជាច្រើនដង រួមទាំងការបង្ខំឱ្យលក់ដីធ្លី ដោយសារពួកគេ មិនអាចសងបំណុល។ ការអនុវត្តបែបនេះ បានបង្ហាញឱ្យឃើញថា អាចផ្តល់ផលចំណេញដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជាអាទិ៍ គ្រាន់តែមីក្រូហិរញ្ញវត្ថុធំជាងគេទាំង៧ អាចរកបានប្រាក់ចំណេញ រហូតដល់លើសពី ១៣០លានដុល្លារ ក្នុងឆ្នាំ ២០១៧។[៦]

កង្វះបទបញ្ញត្តិរបស់រាជរដ្ឋាភិបាល និងការត្រួតពិនិត្យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានធ្វើឱ្យបរាជ័យដល់ការការពារប្រជាជនកម្ពុជាដែលជាអ្នក ខ្ចី ឬរារាំងកំណើននៃវិស័យនេះ។[៧] រាជរដ្ឋាភិបាលតែងលើកសរសើរវិស័យមីក្រូហិរញ្ញវត្ថុ ថាជាផ្នែកសំខាន់ នៃផែនការកាត់បន្ថយភាពក្រីក្រ។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ២០០១-២០០៥ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ ២០០៤-២០០៥ បានគូសបញ្ជាក់ថាវិស័យមីក្រូហិរញ្ញវត្ថុជាផ្នែកសំខាន់របស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។ នាឆ្នាំ ២០០៦ សម្តេចនាយករដ្ឋមន្ត្រីលោកបានប្រកាសថា ឆ្នាំ២០០៦ នេះគឺជា "ឆ្នាំមីក្រូហិរញ្ញវត្ថុ"[៨] ហើយវិស័យនេះនៅតែបន្តរីករាយ ជាមួយបទបញ្ញត្តិធូររលុង និងការគាំទ្រពីគោលនយោបាយជាតិ។ អត្រាការប្រាក់ប្រចាំឆ្នាំអតិបរមា ១៨% ដែលត្រូវបានដាក់ឱ្យប្រើនៅខែមីនា ឆ្នាំ២០១៧ ឃើញថាមិនមានប្រសិទ្ធភាពជួយបន្ធូរបន្ថយ ដល់អ្នកប្រើប្រាស់សេវានោះឡើយ ដោយសារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានចាប់ផ្តើមតម្រូវឱ្យអតិថិជនបង់ថ្លៃសេវាផ្សេងៗ ជាមុនគិតជាភាគរយ នៃចំនួនទឹកប្រាក់កម្ចីដើម្បីធានាថា អត្រាការប្រាក់ជាក់ស្តែង ខ្ពស់ជាងអត្រាការប្រាក់អតិបរមា។

អំពើរំលោភបំពាននៅក្នុងរបាយការណ៍នេះ ភាគច្រើនកើតចេញពីកម្ចីរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន ក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់ មីក្រូឥណទានធំជាងគេ ទាំងប្រាំបួន នៅក្នុងប្រទេសកម្ពុជា ដែលគ្រឹះស្ថានទាំងអស់នេះ គ្របដណ្តប់ ៩០ភាគរយ នៃវិស័យនេះ ។ នេះមានន័យថាការរំលោភបំពាន មិនមែនកើតចេញពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតែមួយនោះឡើយ ផ្ទុយទៅវិញ វាគឺជាផ្នែកដ៏សំខាន់ នៃបទដ្ឋានធុរកិច្ចមីក្រូហិរញ្ញវត្ថុ នៅប្រទេសកម្ពុជា។ ករណីជាច្រើន ដែលបានកត់ត្រាដោយអ្នក ស្រាវជ្រាវសម្រាប់របាយការណ៍នេះមានពាក់ព័ន្ធនឹង បុគ្គលិកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបញ្ឆោអតិថិជន ឱ្យលក់ដីធ្លី និងគំរាមចាត់វិធានការតាមផ្លូវច្បាប់ ប្រសិនបើពួកគេមិនព្រមធ្វើតាម។ ការគំរាមកំហែងនេះ មានលក្ខណៈធ្ងន់ធ្ងរសម្រាប់អតិថិជនដោយសារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានប័ណ្ណកម្មសិទ្ធិដីធ្លីរបស់ពួកគេ។ អតីតថ្នាក់ដឹកនាំ និងថ្នាក់ដឹកនាំបច្ចុប្បន្នរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីររូប ដែលមានបទពិសោធន៍ ជាង២០ឆ្នាំក្នុងវិស័យនេះ បានប្រាប់អ្នកស្រាវជ្រាវឱ្យដឹងថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាក់សម្ពាធជាទៀងទាត់ ដល់អតិថិជនរបស់ខ្លួនឱ្យលក់ដីដើម្បីសងប្រាក់កម្ចីរបស់ពួកគេ។ ក្រោមលក្ខខណ្ឌ រក្សាអនាមិកភាពរបស់ពួកគាត់ ថ្នាក់ដឹកនាំទាំងពីរនេះ បានរៀបរាប់អំពីការប្រើប្រាស់អាជ្ញាធរមូលដ្ឋាន ជាទូទៅដើម្បី បង្កើនសម្ពាធនៅពេលចាំបាច់។

ហេតុដូចនេះ ករណីបំភិតបំភ័យ និងការបង្ខិតបង្ខំឱ្យលក់ដីធ្លីដែលអ្នកស្រាវជ្រាវបានសង្កេតឃើញ មិនមែនជាហេតុការណ៍ដាច់ដោយឡែកកើតឡើងដោយសារតែមន្ត្រីឥណទានម្នាក់ៗនោះឡើយ ផ្ទុយទៅវិញ វាហាក់ដូចជាទម្លាប់អនុវត្តទូទៅនៅក្នុងវិស័យនេះ។

[៦] ទិន្នន័យប្រមូលពីរបាយការណ៍របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៧។

[៧] សូមមើលផ្នែកការការពារអ្នកប្រើប្រាស់និងច្បាប់បញ្ញត្តិ ខាងក្រោម។

[៨] David J. Norman "យុទ្ធសាស្ត្របែបសេរីនិយមថ្មីក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា៖ ករណីមីក្រូហិរញ្ញវត្ថុ ការផ្លាស់ប្តូររូបរាងសេដ្ឋកិច្ចរបស់កម្ពុជា កែសម្រួលដោយ . & K. Un វិទ្យាស្ថាន Nordic Institute of Asian Studies ទំព័រទី១៦៦ ឆ្នាំ២០១១។

ទោះជាមានបញ្ហាទាំងនេះក្តី មីក្រូហិរញ្ញវត្ថុនៅតែបន្ត ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ ពីម្ចាស់ជំនួយទ្វេភាគីធំៗ របស់ប្រទេសកម្ពុជា រួមមានដូចជា សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ របស់ធនាគារពិភពលោក ភ្នាក់ងារអភិវឌ្ឍន៍សហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប និងធនាគារអភិវឌ្ឍន៍របស់រដ្ឋនៅសហគមន៍អឺរ៉ុប ដែលបានផ្តល់ទុនរាប់លានដុល្លារ ដើម្បីពង្រីកវិស័យមីក្រូហិរញ្ញវត្ថុរបស់កម្ពុជា ហើយពេលខ្លះម្ចាស់ជំនួយទាំងនេះ ក៏កាន់កាប់ភាគហ៊ុននៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាផងដែរ។[៩]

បញ្ហានៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា នៅតែមិនទាន់មានការរាយការណ៍ និងសិក្សាឱ្យបានគ្រប់គ្រាន់។ អំពើរំលោភបំពានមិ នត្រូវបានបង្ហាញ នៅក្នុងរបាយការណ៍តុល្យភាព ឬរបាយការណ៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលជាហេតុនាំឱ្យបញ្ហាទាំងនេះ ត្រូវបានលាក់បាំងជិត ។ នាដើមឆ្នាំ២០១៧ បញ្ញវន្តមួយចំនួនបានលើកឡើងនូវការភ័យព្រួយអំពី "ការដួលរលំនៃឥណទានមីក្រូហិរញ្ញវត្ថុ" និងបានបញ្ជាក់ថាមីក្រូហិរញ្ញវត្ថុកំពុងតែ "ដកយកកម្មសិទ្ធិដីធ្លីពីប្រជាជនក្រីក្រសន្សឹមៗ"។[១០] បញ្ហាមួយចំនួនត្រូវបានរកឃើញ ដោយម្ចាស់ភាគហ៊ុនផ្ទាល់ តែមិនដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈ ឬរាយការណ៍ក្នុងរបាយការណ៍ឡើយ។ ជាអាទិ៍ របាយការណ៍ខែតុលាឆ្នាំ២០១៧ ស្តីអំពីភាពជំពាក់បំណុលច្រើនលើសលប់នៅប្រទេសកម្ពុជា ដែលធ្វើឡើងដោយមានការគាំទ្រ ពីភ្នាក់ងារអភិវឌ្ឍន៍នៃក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ អាល្លឺម៉ង់ (BMZ) និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ KfW បានស្ទង់មតិអតិថិជនរបស់មីក្រូហិរញ្ញវត្ថុកម្ពុជា ជាង ១,៦៦០នាក់។ របាយការណ៍នេះបានបង្ហាញថា ៥០ភាគរយ នៃអ្នកខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុ ជំពាក់បំណុលច្រើនលើសលប់។ ភស្តុតាងបង្ហាញថា ប្រជាពលរដ្ឋក្រីក្រកម្ពុជា កំពុងរងការលំបាក ដោយ ៥៥ភាគរយ នៃអតិថិជនដែលជំពាក់ឥណទានកសិកម្ម បានរាយការណ៍ថា ពួកគេបរិភោគអាហារមានគុណភាពទាបជាងមុន ខណៈដែល៤៧ភាគរយ កាត់បន្ថយបរិមាណអាហារដែលពួកគេបរិភោគដើម្បីដោះស្រាយបំណុលរបស់ពួកគេ។ ទោះជាមានការរកឃើញបញ្ហាទាំងនេះ ក៏ដូចជាបញ្ហាគួរឱ្យបារម្ភផ្សេងទៀតក្តី របាយការណ៍ឆ្នាំ ២០១៧នេះ មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយ។ ភ្នាក់ងារ អភិវឌ្ឍន៍នៃក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ អាឡឺម៉ង់ (BMZ) និង ធនាគារអភិវឌ្ឍន៍ អាឡឺម៉ង់ KfW បានបន្តផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ដល់វិស័យ មីក្រូហិរញ្ញវត្ថុកម្ពុជា ដែលកើនឡើងលើស ៣០ភាគរយ នៅឆ្នាំ បន្ទាប់ ក្រោយរបាយការណ៍នេះបោះពុម្ពផ្សាយ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលកំពុងធ្វើប្រតិបត្តិការបច្ចុប្បន្ននេះ បានបង្កជាការគំរាមកំហែង ដល់សុវត្ថិភាព នៃសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋ រាប់លាននាក់នៅប្រទេសកម្ពុជា។ យ៉ាងតិចណាស់ ៥០ភាគរយនៃគ្រួសារទាំងអស់ នៅក្នុងខេត្តនីមួយៗ លើកលែងតែរាជធានីភ្នំពេញ ជំពាក់កម្ចីមីក្រូហិរញ្ញវត្ថុ ដែលអ្នកទាំងនោះភាគច្រើន មានដាក់ប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លី ជាការធានា ហើយនៅក្នុងខេត្តមួយចំនួន មានលើសពី ៨០ភាគរយនៃគ្រួសារ។[១១] កំណើនយ៉ាងឆាប់រហ័សនៃវិស័យនេះ បរិយាកាសបទបញ្ញត្តិធូររលុង និងការទាមទារឱ្យមានកំណើនអ្នកវិនិយោគបរទេស បាននាំឱ្យមានការរំលោភបំពាន ការបាត់បង់ដីធ្លី និងការកេងប្រវ័ញ្ចទៅលើអតិថិជនរបស់មីក្រូហិរញ្ញវត្ថុនៅទូទាំងប្រទេស។

[៩] សូមមើលផ្នែកភាពជាកម្មសិទ្ធិ ខាងក្រោម។

[១០] Milford Bateman មតិយោបល់៖ " វិស័យមីក្រូឥណទានជួបបញ្ហាដែលបង្កើតឡើងដោយខ្លួនឯង កាសែតខាំបូឌាដេលី ចុះផ្សាយនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧ " https://www.cambodiadaily.com/news/opinion-microcredit-sector-hits-wall-making-129618/

[១១] "ការសិក្សាពីភាពជំពាក់បំណុលច្រើនលើសលប់កម្ពុជា ២" ខែតុលា ឆ្នាំ២០១៧

មីក្រូហិរញ្ញវត្ថុ បានចាប់ផ្តើមមាននៅប្រទេសកម្ពុជាចាប់ពីឆ្នាំ ១៩៩០ ក្នុងរូបភាពជាគម្រោងអភិវឌ្ឍន៍អន្តរជាតិ ដែលផ្តល់ឥណទានដល់ប្រជាពលរដ្ឋក្រីក្រ ដើម្បីឱ្យពួកគេមានលទ្ធភាពបង្កើតមុខរបរខ្នាតតូច។ នៅខែមករា ឆ្នាំ១៩៩៣ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ និងអង្គការពលកម្មអន្តរជាតិ បានធ្វើកិច្ចសហការបង្កើតសមាគមភ្នាក់ងារ អភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងស្រុក (អេស៊ីលីដា)។ អេស៊ីលីដា បានក្លាយខ្លួនទៅជា ធនាគារពាណិជ្ជធំជាងគេ នៅក្នុងប្រទេស និងបច្ចុប្បន្នមានគុល្យភាពឥណទាន លើសពី ៣ពាន់លានដុល្លារ ក្នុងនោះ ១,៦ពាន់លានដុល្លារ គឺសម្រាប់ឥណទានខ្នាតតូច។ ការផ្លាស់ប្តូរនេះ អាចធ្វើទៅបាន ក៏ដោយសារតែមានជំនួយផ្នែកហិរញ្ញវត្ថុ និង បច្ចេកទេស ពីអង្គការសហប្រជាជាតិ (UN) សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និង ភ្នាក់ងារអភិវឌ្ឍន៍សហរដ្ឋអាមេរិក (USAID) និងសហភាពអឺរ៉ុប (EU)។[១២]

វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ចាប់ផ្តើមរីកលូតលាស់នៅឆ្នាំ២០០០ ហើយចាប់ពីឆ្នាំ ២០០៩មក មានការផ្ទុះឡើងនូវ ការវិនិយោគពីបរទេស ធ្វើឱ្យវិស័យនេះរីកចម្រើនយ៉ាងឆាប់រហ័ស ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ នាដើមឆ្នាំ២០១៩ មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាង ៨០ ដែលបានចុះបញ្ជីឈ្មោះ ជាមួយនឹងធនាគារជាតិកម្ពុជា រួមមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើពីសាធារណជនធំៗទាំងប្រាំពីរ។[១៣] តួលេខនេះមិនរាប់បញ្ចូលប្រតិបត្តិការឥណទានជនបទ និងអង្គការមិនមែនរដ្ឋាភិបាលតូចៗរាប់រយទៀត ដែលផ្តល់ឥណទានខ្នាតតូចឡើយ។

គុល្យភាពឥណទាន របស់មីក្រូហិរញ្ញវត្ថុផ្លូវការ កើនឡើងពីប្រមាណ ៣០០លានដុល្លារ ក្នុងឆ្នាំ២០០៩ ដល់១,៣ពាន់លានដុល្លារ នៅឆ្នាំ ២០១៣ និងកើនដល់ ប្រមាណ៥,៤ពាន់លានដុល្លារ នាចុងឆ្នាំ ២០១៨។[១៤] ដោយគិតរួមបញ្ចូលទាំង "គុល្យភាពមីក្រូឥណទាន" របស់ធនាគារអេស៊ីលីដា និងធនាគារស្ថាបនា ដែលជាធនាគារពាណិជ្ជ ចូលរួមក្នុងទីផ្សារមីក្រូឥណទាន គុល្យភាពមីក្រូឥណទានសរុបកើនដល់ ៨ពាន់លានដុល្លារ។ ចំនួនទឹកប្រាក់កម្ចី ៨ពាន់លានដុល្លារនេះ ស្ថិតនៅក្នុងដៃអ្នកខ្ចីចំនួន ២,៤លាននាក់នៅទូទាំងប្រទេស។

កំណើនដ៏គួរឱ្យភ្ញាក់ផ្អើលនេះ បានកើនហួសសមត្ថភាពរបស់អ្នកខ្ចីក្នុងការសងប្រាក់កម្ចី។ ក្នុងចន្លោះ ឆ្នាំ២០០៤ និង ២០១៨ទំហំឥណទានមធ្យមរបស់ មីក្រូហិរញ្ញវត្ថុ កើនឡើងបួនដង នៃចំណូលរបស់

ភាគបែងនៃឥណទានតាមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
(គិតជាដុល្លារអាមេរិក)




គ្រួសារ។[១៥] សម្រាប់គ្រួសារនៅជនបទ ទំហំឥណទានមធ្យមកំពុងតែកើនឡើង តាមចំណូលមធ្យមរបស់គ្រួសារ និង លើសពីទ្វេដង នៃផលិតផលក្នុងស្រុក សរុបក្នុងមនុស្សម្នាក់។ ក្នុងចន្លោះឆ្នាំ ២០១៥ និង២០១៧ ទំហំឥណទានមធ្យមបានកើនឡើង ដល់ទៅ ៨០ភាគរយ។[១៦] កំណើននេះនៅតែមានបន្ត ដោយនៅក្នុងឆ្នាំ ២០១៨ គុល្យភាពឥណទាន សរុបរបស់មីក្រូហិរញ្ញវត្ថុ កើនឡើងលើសពី ៣០ភាគរយ។[១៧] នៅក្នុងឆ្នាំដដែល មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានរាយការណ៍ថា "សារៈសំខាន់ នៃការរីកលូតលាស់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅតែបន្តបង្កជាហានិភ័យដល់ ស្ថេរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច"។[១៨]

[១២] "ប្រវត្តិ" អេស៊ីលីដា https://www.acledabank.com.kh/kh/eng/ff_history

[១៣] តាមលំដាប់ទំហំគុល្យភាពឥណទាន ពីធំទៅតូច៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ អិលអូអិលស៊ី (ខេមបូឌា) អង្គរមីក្រូហិរញ្ញវត្ថុ កម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត ដាប់ប៊ែលយូប៊ី ហ្វាយនែន

[១៤] ទិន្នន័យពីរបាយការណ៍ប្រចាំឆ្នាំរបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

កំណើននេះ បានផ្តល់ប្រាក់ចំណេញ យ៉ាងសម្បើម ដល់ម្ចាស់ភាគហ៊ុន របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងដៃគូ ផ្តល់ប្រាក់កម្ចី។ ប្រាក់ចំណេញនៅតែបន្តមាន ទោះជាធនាគារជាតិនៃកម្ពុជាបានចេញប្រកាស ឬបទបញ្ញត្តិ សម្រាប់ប្រតិបត្តិ នៅខែមីនា ឆ្នាំ ២០១៧ ដោយកំណត់អត្រាការប្រាក់ អតិបរមា សម្រាប់កម្ចីពីមីក្រូហិរញ្ញវត្ថុ ត្រឹម ១៨ភាគរយ ក្នុងមួយឆ្នាំ ខណៈដែលនេះជាការរក្សាអត្រាការប្រាក់ខ្ពស់របស់កម្ចីពីមុន។ ប្រាក់ចំណេញនេះភាគច្រើន គឺបានទៅលើ ស្ថាប័នហិរញ្ញវត្ថុចំនួនប្រាំបួន រួមមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជនទាំងប្រាំពីរ និងធនាគារអេស៊ីលីដា ហើយនិងធនាគារស្ថាបនា ដែលស្ថាប័នទាំងអស់នេះ មានតុល្យភាពមីក្រូឥណទាន លើសពី ៩០ ភាគរយនៃមីក្រូឥណទានទាំងអស់នៅក្នុងប្រទេស។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំៗទាំងអស់ កាន់កាប់ដោយស្ថាប័នបរទេសទាំងស្រុង ឬដែលមានភាគហ៊ុនច្រើន លើកលែងធនាគារអេស៊ីលីដា ដែលមា នភាគហ៊ុន ៥១ភាគរយជារបស់ខ្មែរ។ ប៉ុន្មានឆ្នាំកន្លងមកនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើន ត្រូវបានទិញយកដោយ វិនិយោគិនបរទេស ដោយសារផលចំណេញពីវិស័យនេះ បានទាក់ទាញទុនវិនិយោគពីក្រៅប្រទេស។ ម្ចាស់ភាគហ៊ុនធំៗនៅក្នុងស្ថាប័នទាំងនេះ រួមមានសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិរបស់ធនាគារពិភពលោក (IFC) ភ្នាក់ងារអភិវឌ្ឍន៍អឺរ៉ុប(EU) និងស្ថាប័នធនាគារឯកជនដែលរកម្រៃបានខ្ពស់។

---

[១៥] "ប្រទេសកម្ពុជា៖ ការខ្ចីជាច្រើនដង និងទំហំកម្ចី សន្ទស្សន៍មីក្រូហិរញ្ញវត្ថុស្តីពីការរីកនិងភាពឆ្អែតនៃទីផ្សារ ទំព័រទី២ ខែមិថុនា ឆ្នាំ២០១៦ https://cma-network.org/files/OIDWORKSHOP/MIMOSA%20Circular%20%20Cambodia%20Jun%202016.pdf

[១៦] មីក្រូហិរញ្ញវត្ថុ និងសុខមាលភាពគ្រួសារ៖ ឯកសារគោលនយោបាយកម្ពុជា ធនាគារពិភពលោកគ្រុប ទំព័រទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ http://documents.worldbank.org/curated/en/144661552916327946/pdf/128266-REVISED-WP-PUBLIC-Nota-MFI-web.pdf

[១៧] សុខ ចាន់ ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរីកលូតលាស់ក្នុងកម្រិតល្អ៖ ធនាគារកណ្តាល ខ្មែរថាម ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ https://www.khmertimeskh.com/50572675/banks-and-mfis-growing-at-a-healthy-rate-central-bank/

[១៨] "ក្រុមការងារមូលនិធិរូបិយវត្ថុអន្តរជាតិមកបំពេញបេសកកម្មមាត្រា៤នៅកម្ពុជាក្នុងឆ្នាំ២០១៨" មូលនិធិរូបិយវត្ថុអន្តរជាតិ ថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨ https://www.imf.org/en/News/Articles/2018/10/02/PR18371Cambodia.

[១៩] ប្រកាសស្តីពីការដាក់ពិដានអត្រាការប្រាក់ឥណទាន ឆ្នាំ២០១៧

# វិធីសាស្ត្រ

អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ និង សមាគមធាងត្នោត មានបទពិសោធន៍ ច្រើនទសវត្សរ៍ក្នុងការកត់ត្រាស្ថានភាពរាប់រយពាន់របស់ប្រជាពលរដ្ឋខ្មែរ ដែលបាន បាត់បង់ដីធ្លីរបស់ពួកគេ ដោយសារការឆ្លៀតឱកាសកេងចំណេញពីបុគ្គល និងស្ថាប័នដែលមានអំណាច។

ការសិក្សាស្រាវជ្រាវ ដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ធ្វើឡើងនៅក្នុងឃុំចំនួន ១០ ក្នុងខេត្តចំនួនបួន រួមមានខេត្តកំពង់ចាម ខេត្តកណ្តាល ខេត្តព្រៃវែង និងខេត្តត្បូងឃ្មុំ និងរាជធានីភ្នំពេញ។ កិច្ចសម្ភាសន៍ ត្រូវបានធ្វើឡើង ក្នុងរយៈពេលបីសប្តាហ៍ ពីចន្លោះខែមីនា និង ខែឧសភា ឆ្នាំ២០១៩។ ក្រុមអ្នកស្រាវជ្រាវពីរក្រុម ធ្វើការសម្ភាសដំបូង ដើម្បីកំណត់ និងជ្រើសរើសបុគ្គល ដែលធ្លាប់រងគ្រោះ ពីអំពើរំលោភបំពានសិទ្ធិមនុស្ស ដោយសារបំណុលមីក្រូហិរញ្ញវត្ថុ។ អ្នកដែលត្រូវបានសម្ភាសលើកដំបូង ស្ទើរតែទាំងអស់ធ្លាប់ទទួលរងគ្រោះនៃការរំលោភបំពានម្តង ឬច្រើនលើកច្រើនសារ។ ក្រុមអ្នកស្រាវជ្រាវ កំណត់បាន នូវករណីចំនួន ២៨ នៃអំពើរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ឬច្រើនដង ដែលបណ្តាលមកពីការជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ។ បន្ទាប់មក ក្រុមអ្នកស្រាវជ្រាវ ធ្វើការសម្ភាសស៊ីជម្រៅលក្ខណៈពាក់កណ្តាលរចនាសម្ព័ន្ធ ជាមួយនឹងបុគ្គលដែលរងគ្រោះ។ សំណួរ ដែលសួរទាក់ទងទៅនឹងប្រវត្តិ នៃការយកឥណទាន ពីមីក្រូហិរញ្ញវត្ថុ បទពិសោធន៍ក្នុងការដកយកឥណទាន ប្រវត្តិមុខរបរនិងចំណូល បទពិសោធន៍ទូទាត់សងបំណុល និងបញ្ហាដែលកើតមានឡើង ដោយសារបំណុលនៅក្នុងគ្រួសារ ឬសហគមន៍។ ក្រុមអ្នកស្រាវជ្រាវធ្វើកំណត់ត្រា ហើយផ្នែកខ្លះ ថតទុកជាសំឡេងនៃកិច្ចសម្ភាសន៍ ដែលមានរយៈពេលប្រមាណមួយម៉ោង។ ក្រុមអ្នកស្រាវជ្រាវ ជូនព័ត៌មានជាមុនដល់អ្នកដែលត្រូវបានសម្ភាសន៍ អំពីការបោះពុម្ពផ្សាយខ្លឹមសារនៃកិច្ចសម្ភាសន៍ ដោយមិនបញ្ចេញព័ត៌មាន អំពីអត្តសញ្ញាណដូចជា ឈ្មោះ ឬឃុំរបស់ពួកគេ។ ក្រុមអ្នកស្រាវជ្រាវធ្វើការពន្យល់ប្រធានបទ នៃការសិក្សាស្រាវជ្រាវ និងទទួលបានការយល់ព្រមដោយផ្ទាល់មាត់ ពីអ្នកចូលរួមក្នុងបទសម្ភាសន៍ ឱ្យកត់ត្រាទុកចម្លើយរបស់ពួកគេ មុនពេលកិច្ចសម្ភាសន៍នីមួយៗចាប់ផ្តើម។

ទីកន្លែងសម្រាប់ការសិក្សានេះ ត្រូវបានជ្រើសរើសផ្អែកតាមចំនួនឥណទានក្នុងមួយគ្រួសារ និង/ឬ ផលធៀបធំរវាងឥណទានមិនដំណើរការនឹងចំនួនឥណទានសរុបនៅក្នុងតំបន់។ ក្រុមអ្នកស្រាវជ្រាវស្វែងរកតំបន់ដែលជំពាក់បំណុលច្រើន និងដេញតាមករណីបាត់បង់ដីធ្លីដោយសារឥណទាន ពីមីក្រូហិរញ្ញវត្ថុ។ អតីតថ្នាក់ដឹកនាំ និងថ្នាក់ដឹកនាំបច្ចុប្បន្នរបស់មីក្រូហិរញ្ញវត្ថុពីររូប ដែលមានបទពិសោធន៍ជាង ២០ឆ្នាំ នៅក្នុងវិស័យនេះក៏បានផ្តល់បទសម្ភាសន៍រយៈពេលរាប់ម៉ោង និង រៀបរាប់ឥតលាក់លៀម ពីការអនុវត្តទូទៅនៅក្នុងវិស័យនេះ ក្នុងលក្ខខណ្ឌរក្សាអនាមិកភាពរបស់ពួកគេ។

ខណៈដែលការសិក្សានេះធ្វើឡើង ដោយមានការគិតពីបញ្ហាយេនឌ័រ ការសិក្សានាថ្ងៃមុខអំពីតួនាទីដែលយេនឌ័រ មានក្នុងការដោះស្រាយបំណុលមីក្រូហិរញ្ញវត្ថុ នឹងផ្តល់អត្ថប្រយោជន៍ ដល់ការស្វែងយល់ថាឥណទានទាំងនេះប៉ះពាល់ដល់ស្ត្រី និងបុរសខុសគ្នាយ៉ាងដូចម្តេចខ្លះ។ អ្នកស្រាវជ្រាវបានរកឃើញថា អតិថិជនរបស់មីក្រូហិរញ្ញវត្ថុយល់ថាបំណុល គឺជាបញ្ហាគ្រួសារ។ នៅក្នុងគ្រួសារដែលមានប្តីនិងប្រពន្ធ ពួកគេទាំងពីរ ត្រូវបានជូនព័ត៌មាន អំពីបំណុលជាមុនហើយពួកគេទាំងពីរនេះធ្វើការដើម្បីសងបំណុលនេះ។ ទោះជាយ៉ាងនេះក្តី មានវិសមមាត្ររវាងយេនឌ័រ នៅក្នុងការផ្តល់កម្ចីរបស់មីក្រូហិរញ្ញវត្ថុដោយប្រមាណ ៧៥ភាគរយ នៃអតិថិជនរបស់មីក្រូហិរញ្ញវត្ថុគឺជាស្ត្រី ហើយមូលនិធិពីភ្នាក់ងារអភិវឌ្ឍន៍របស់លោកខាងលិចខ្លះផ្តល់មកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តាមរយៈកម្មវិធីអភិវឌ្ឍន៍យេនឌ័រ។ ជាទម្លាប់យូរមកហើយ ស្ត្រីនៅកម្ពុជា គឺជាអ្នកចាត់ចែងហិរញ្ញវត្ថុគ្រួសារ ដូចនេះចាំបាច់ត្រូវមានការសិក្សាវិភាគយេនឌ័រ ស៊ីជម្រៅអំពីបំណុលមីក្រូហិរញ្ញវត្ថុ។

គួរកត់សម្គាល់ថា ការសិក្សានេះ មិនបានធ្វើឡើងក្នុងគោលបំណងជាសំណាកតំណាងទូទាំងប្រទេសកម្ពុជា ឬសំណាក អតិថិជនទាំងអស់របស់មីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសឡើយ ប៉ុន្តែដើម្បីលើកយកបញ្ហាដែលអ្នកស្រាវជ្រាវរកឃើញនៅក្នុងតំបន់គោលដៅ ដូចជាបញ្ហាបាត់បង់ដីធ្លីដែលបង្ហាញឱ្យឃើញច្បាស់ ពីការគាបសង្កត់លើ សិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋក្រីក្រ។ ការសិក្សានាថ្ងៃអនាគតត្រូវមានជាចាំបាច់ដើម្បីកំណត់ទំហំពិតប្រាកដនិងភាពធ្ងន់ធ្ងរនៃបញ្ហាដែលបានលើកឡើងក្នុងរបាយការណ៍នេះ។



# ការរកឃើញនៃការសិក្សា

## ការអនុវត្តផ្តល់ប្រាក់កម្ចីគ្មានក្រមសីលធម៌

ការរកឃើញនៃការសិក្សាស្រាវជ្រាវនេះ បង្ហាញថារាល់ទំនាក់ទំនងផ្ទាល់រវាងអតិថិជន ជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ទើរតែធ្វើឡើងតាមរយៈ មន្ត្រីឥណទាន។ មន្ត្រីទាំងនេះ ចុះតាមភូមិ ដើម្បីផ្តល់ឥណទាននិងចុះកិច្ចសន្យា ហើយពួកគេចុះទៅ ទូទាត់ប្រាក់ជារៀងរាល់ខែ តាមពេលកំណត់ ។ ដូចគ្នានឹងបណ្តាប្រទេសជាច្រើនផ្សេងទៀត ដែលមានវិស័យមីក្រូហិរញ្ញវត្ថុ ដើរតួនាទីសំខាន់[២០] មន្ត្រីឥណទាន តែងតែទទួលសម្ពាធពីថ្នាក់លើដែលតម្រូវឱ្យពួកគេ សម្រេចបានចំនួនកូតានៃការផ្តល់កម្ចីប្រចាំខែ និង ធានាឱ្យបានថាប្រាក់កម្ចីទាំងនេះ ត្រូវបានសងត្រឡប់មកវិញទៀងទាត់ពេល ទោះជាពេលខ្លះ ពួកគេត្រូវចេញឥណទានថ្មី ធំជាងមុនឱ្យអតិថិជន ឬបង្ខំឱ្យអតិថិជនលក់ដី ក៏ដោយ។ គំនាបសង្កត់លើមន្ត្រីឥណទានថ្នាក់ទាប នេះ តែងតែធ្លាក់លើអតិថិជន តាមរយៈការប្រព្រឹត្តិនូវទង្វើឆ្លៀតឱកាសកេងចំណេញ ឬគ្មានក្រមសីលធម៌ ដែលកើតឡើងជាច្រើន លើកច្រើនដងលើអតិថិជន នេះផ្អែកតាមការរាយការណ៍ប្រាប់ក្នុងកិច្ចសម្ភាសន៍ជាមួយអតិថិជន។

> "ខ្ញុំ ប្រាដកជាសប្បាយចិត្តខ្លាំងណាស់ ប្រសិនជាសាររបស់ខ្ញុំនេះបានលឺដល់សហគមន៍អឺរ៉ុប៖ ប្រសិនបើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅតែបន្តគាបសង្កត់មកលើកសិករដូចជារូបខ្ញុំនេះ យើងនឹងបន្តបាត់បង់ដីធ្លីរបស់ពួកយើងជាមិនខាន"
> - កសិករនៅខេត្តត្បូងឃ្មុំ

អ្នកស្រាវជ្រាវ បានកត់ត្រាករណីចំនួន១០ ក្នុងនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានឱ្យប្រាក់កម្ចី ដល់ប្រជាពលរដ្ឋ ទោះជាដឹងច្បាស់ថាប្រាក់កម្ចីនេះ នឹងយកទៅទូទាត់សងបំណុលចាស់ ក៏ដោយ។ ក្នុងករណីខ្លះ កម្ចីត្រូវបានផ្តល់ដល់អតិថិជន ទោះបីជាមន្ត្រីឥណទានដឹងថាអ្នកខ្ចី មិនអាចមានលទ្ធភាពសងប្រាក់កម្ចី។ មានករណីមួយ អតិថិជនរបស់ធនាគារស្ថាបនា មិនបានបង់ប្រាក់រយៈពេល ១៥ថ្ងៃក្រោយពេលកំណត់។ មន្ត្រីឥណទានបានមកប្រាប់អតិថិជននោះ ឱ្យលក់ដី ឬចងការប្រាក់កម្ចីឯកជន ដើម្បីយកមកទូទាត់បំណុល។ អតិថិជននោះបានធ្វើតាមដោយលក់ដី និងទៅចងការប្រាក់ឯកជន ដើម្បីសងប្រាក់កម្ចី។ បីថ្ងៃក្រោយបន្ទាប់ពីបានទូទាត់សងបំណុលអស់ ដោយមានក្តីបារម្ភ ពីបញ្ហាចិញ្ចឹមកូនរបស់គាត់អតិថិជនរូបនេះ ក៏ត្រឡប់ទៅធនាគារស្ថាបនា ម្តងទៀតហើយ មន្ត្រីឥណទានដដែល បានផ្តល់កម្ចីបន្ថែម និងច្រើនជាងមុនដល់គាត់។

នៅក្នុងករណីខ្លះទៀត កង្វះបទបញ្ញត្តិ និងរបៀបដែលវិស័យមីក្រូហិរញ្ញវត្ថុ ស្វែងរកប្រាក់ចំណេញ បានចូលរួមជម្រុញឱ្យមានការអនុវត្តផ្តល់ប្រាក់កម្ចីមិនត្រឹមត្រូវ ដែលគួរតែជៀសវាង។

### ករណីសិក្សាអំពីការអនុវត្តផ្តល់ប្រាក់កម្ចីគ្មានក្រមសីលធម៌

សុខា[២១] គឺជាឪពុកម្នាក់ដែលមានកូនប្រាំនាក់ និងប្រកបរបរជាកសិករដាំដំឡូងមី។ គាត់បានយកប្រាក់កម្ចីដំបូងចំនួន ៣,២៥០ដុល្លារ ពីធនាគារស្ថាបនានៅឆ្នាំ ២០១៦ ដើម្បីទិញម៉ាស៊ីនធ្វើចំការដំណាំដំឡូង។ គាត់បានដាក់តម្កល់ដីស្រែមួយហិចតាជាទ្រព្យបញ្ចាំប្រាក់កម្ចី។ នៅពេលតម្លៃដំឡូងមីចាប់ផ្តើមធ្លាក់ចុះខ្លាំង និងដល់ពេលត្រូវ ទូទាត់បង់ប្រាក់ដើម គាត់មិនមានលទ្ធភាពបង់ប្រាក់ឡើយ ។

បន្ទាប់ពីខកខានបង់ប្រាក់លើកទីមួយ មន្ត្រីឥណទានរបស់ធនាគារស្ថាបនា បានទៅផ្ទះគាត់ពីរដងក្នុងរយៈពេល ១៥ថ្ងៃ។ សុខាបានស្នើសុំពន្យារពេលបង់ប្រាក់រយៈពេល មួយខែដើម្បីទុកពេលរកប្រាក់បន្ថែម តែមន្ត្រីនោះទុកពេលឱ្យគាត់តែ ១៥ថ្ងៃប៉ុណ្ណោះ និងបានប្រាប់គាត់ថាប្រសិនជាគាត់មិនលក់ដីទេ ពួកគេនឹង "អនុវត្តតាមផ្លូវច្បាប់ដូចមាន ចែងក្នុងកិច្ចសន្យា"។ សុខាដឹងច្បាស់ថា ប្រសិនជាពួកគេរឹបអូសយកដីរបស់គាត់ ហើយដាក់លក់ក្នុងតម្លៃទាបជាងតម្លៃទីផ្សារ ដូចនេះគាត់ក៏បានលក់ដីមួយចំណែកដោយខ្លួនឯង និងចងការប្រាក់មិនផ្លូវការចំនួនពីរទៀតដើម្បីសងផ្តាច់ប្រាក់កម្ចីរបស់ធនាគារស្ថាបនា។

បីថ្ងៃក្រោយមក សុខាបានត្រឡប់ទៅរកធនាគារស្ថាបនាវិញ។ មន្ត្រីឥណទានដដែល បានផ្តល់ប្រាក់កម្ចីចំនួនទឹកប្រាក់ ៣,៥០០ដុល្លារ បន្ថែមទៀត ដោយតម្រូវឱ្យដាក់តម្កល់ដីចំការកាន់តែធំជាងមុនទៀត។ តម្លៃដំណាំធ្លាក់ចុះសារជាថ្មីម្តងទៀត ហើយសុខាក៏បានប្រាប់ទៅ មន្ត្រីឥណទានរបស់ធនាគារស្ថាបនាថាគាត់មិនអាចទូទាត់បង់ប្រាក់ឱ្យបានឡើយ។ មន្ត្រីឥណទានទាំងនោះបានប្រាប់គាត់ឱ្យទៅខ្ចីប្រាក់ពីអ្នកផ្តល់កម្ចីឯកជន ព្រោះថាបើគាត់បង់សងផ្តាច់ប្រាក់ កម្ចីនេះ គាត់នឹងអាចទទួលបានប្រាក់កម្ចីថ្មីច្រើនជាងមុន ហើយគាត់នឹងមិនចាំបាច់ខ្វាយខ្វល់ពីការបង់ប្រាក់ក្នុងរយៈពេលប៉ុន្មានខែ។ សុខាធ្វើតាមអ្វីដែលគេប្រាប់។ ក្រោយពេលគាត់បង់សងផ្តាច់កម្ចីរបស់ធនាគារស្ថាបនា ហើយ គាត់ក៏ទទួលបានប្រាក់កម្ចីថ្មីក្នុងទឹកប្រាក់ចំនួន ៥,០០០ ដុល្លារ។

សព្វថ្ងៃនេះ ដោយសារតម្លៃដំណាំនៅតែទាបហើយជិតដល់ពេលត្រូវបង់រំលោះប្រាក់ដើមផង សុខាបានបង្ខំចិត្តឈប់បញ្ជូនកូនរបស់គាត់ដែលមានអាយុ ១០ឆ្នាំ និង ៧ឆ្នាំ ទៅរៀន ដើម្បីឱ្យជួយនៅធ្វើចំការដំឡូងមីរបស់គាត់។ គាត់ដឹងច្បាស់ថា គាត់នឹងត្រូវបង្ខំចិត្តលក់ដី ដែលនៅសេសសល់របស់គាត់ក្នុងពេលឆាប់ៗនេះ ដើម្បីទូទាត់ សងប្រាក់កម្ចីបច្ចុប្បន្នរបស់គាត់។ គាត់បានខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុជាង ១១,០០០ដុល្លារ គឺដើម្បីតែទិញម៉ាស៊ីនធ្វើចំការដំឡូងរបស់គាត់។ គាត់បាននិយាយថា "ប្រសិន បើខ្ញុំ មិនសងប្រាក់ ពួកគេនឹងលក់ដីចំការខ្ញុំ។ សូមប្រាប់ទៅពួកគាត់ផងថា ប្រសិនជាយើងមិនអាចសងប្រាក់ទាន់ពេលវេលា ពួកគាត់មិនគួររឹបអូសយកដី ឬផ្ទះរបស់យើង ទេ។"

---

[២០] Mathilde Maîtrot "គោលការណ៍នៃចីរភាព និងការប្រាសចាកពីគោលការណ៍៖ ការសិក្សាអំពីជីវភាពអតិថិជនរបស់មីក្រូហិរញ្ញវត្ថុនៅប្រទេសបង់ក្លាដេស ការកើនឡើងនិងធ្លាក់ចុះមីក្រូឥណទានជាសកល៖ ការអភិវឌ្ឍ បំណុលនិងការខកចិត្ត កែសម្រួលដោយ M. Bateman, S. Blankenburg, and R. Kozul-Wright ទំព័រ១៤៣ ដល់១៦៥ (ឆ្នាំ២០០៩) Oxford: Routledge

[២១] ឈ្មោះនេះក៏ដូចជាឈ្មោះផ្សេងទៀតដែលមាននៅក្នុងករណីសិក្សាក្នុងរបាយការណ៍នេះត្រូវបានផ្លាស់ប្តូរដើម្បីការពារអត្តសញ្ញាណរបស់អ្នកផ្ទាល់បទសម្ភាស៍

មានករណីជាច្រើន ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ផ្តល់ប្រាក់កម្ចីទៅគ្រួសារ ដែលមានសមាជិកគ្រួសារឈឺ ដែលបញ្ហានេះ ធ្វើឱ្យចំណូលគ្រួសាររបស់ពួកគេថយចុះ។ ក្នុងករណីមួយចំនួនទៀតនៅពេលអតិថិជន ខកខានមិនបានបង់ប្រាក់ គ្រឹះស្ថានហិរញ្ញវត្ថុបានដឹងតាំងពីដំបូងថា អតិថិជនអាចពុំមាន លទ្ធភាពសងបំណុល តែគ្រឹះស្ថានហិរ ញ្ញវត្ថុនោះ ពុំមានផ្តល់ដំណោះស្រាយសមរម្យណាមួយ ដល់អតិថិជនឡើយធ្វើឱ្យបំណុលរបស់អតិថិជន អាចកើនឡើងរាប់ពាន់ដុល្លារ ដោយសារតែកំណើនការប្រាក់ និងប្រាក់ពិន័យផ្សេងទៀត ។

នៅក្នុងករណីខ្លះទៀត អតិថិជនប្រើប្រាស់កម្ចី ដើម្បីទូទាត់ការចំណាយចាំបាច់ផ្សេងៗ មានដូចជាអាហារ ថ្នាំពេទ្យ សុខភាព ឬការចំណាយ លើការសិក្សារបស់កូន។ ប្រទេសកម្ពុជា នៅខ្វះខាតសេវាសង្គមជាច្រើន ដូចជា សេវាថែទាំសុខភាពពេញលេញ ឬការសិក្សាដោយឥតគិតថ្លៃគ្រប់គ្រាន់ ហើយកម្ចីពីមីក្រូហិរញ្ញវត្ថុត្រូវបានប្រើប្រាស់ម្តងម្កាល សម្រាប់ចំណាយដើម្បីសុខភាព និងការរស់នៅប្រកបដោយភាពថ្លៃថ្នូរ។ កិច្ចសន្យាដែលអាចយកជាផ្លូវការបានតម្រូវឱ្យភាគីទាំងពីរយល់ព្រមដោយសេរី និងគ្មានការបង្ខិតបង្ខំពីកត្តាខាងក្រៅ ប៉ុន្តែស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច របស់អ្នកខ្ចី ប្រាក់ពីមីក្រូហិរញ្ញវត្ថុជាច្រើន បានបង្កជាសំណួរថា តើការ ខ្ចីប្រាក់ដើម្បីចិញ្ចឹម កូន ឬបញ្ជូនសាច់ញាតិ ទៅមន្ទីរពេទ្យអាចចាត់ទុកថាជាជម្រើសដោយ ស្ម័គ្រចិត្ត មិនមានការបង្ខំ ឬយ៉ាងណា?

## ការលក់ដីដោយបង្ខំ

ក្នុងចំណោមករណីសិក្សាចំនួន២៨ករណី យ៉ាងហោចណាស់ក៏មាន ២២ករណី ពាក់ព័ន្ធនឹងការលក់ដីដោយបង្ខំ នេះជាភាគរយដ៏ខ្ពស់គួរឱ្យចាំ អារម្មណ៍ ដែលជាក្តីបារម្ភខ្លាំង ទៅលើការបាត់បង់ដីធ្លីដោយសារ វិស័យមីក្រូហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា។ អ្វីដែលគួរឱ្យកត់សម្គាល់ គឺសារៈសំខាន់នៃដីធ្លី សម្រាប់ប្រជាពលរដ្ឋដែលត្រូវគេបង្ខំឱ្យលក់ដី។ នៅក្នុងករណីភាគច្រើន ដីធ្លីដែលបាត់បង់ គឺធ្លាប់ប្រើ ដើម្បីបង្កើតប្រាក់ចំណូល ដោយប្រើប្រាស់សម្រាប់ដាំដំណាំ ឬ ចិញ្ចឹមគោ។ សម្រាប់ប្រជាពលរដ្ឋក្រីក្រ នៅទីជនបទដែលជាក្រុមកូនបំណុលចម្បង ដីពិតជាមានសារៈសំខាន់ ចំពោះជីវភាពរស់នៅប្រចាំថ្ងៃ ជាពិសេស គឺចំពោះប្រជាពលរដ្ឋ ដែលជាកសិករ។ ប្រជាពលរដ្ឋកម្ពុជារស់នៅទីជនបទ ពឹងពាក់លើដី ដើម្បីចិញ្ចឹមជីវិត បើគ្មានដីពួកគេក៏គ្មានមធ្យោបាយ ដើម្បីរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់ជីវភាពទៀតនោះដែរ។ ដូច្នេះការបាត់បង់ដីធ្លី គឺមិនមែនបានន័យថា ជាការផ្ទេរទ្រព្យពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតនោះទេ តែជាគ្រោះថ្នាក់ដល់ជីវភាពគ្រួសារ មុខរបរ និងអត្តសញ្ញាណរបស់ពួកគេ។

ពាក្យថាលក់ដីដោយបង្ខិតបង្ខំ គឺជាការបង្ខំឱ្យលក់ដីដោយការគំរាមគំហែងការបំភិតបំភ័យ ដោយការបញ្ឆោ ឬការដាក់សម្ពាធដោយផ្ទាល់ពីបុគ្គលិកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីឱ្យអតិថិជនលក់ដី ដើម្បីបានប្រាក់សងបំណុល។ ការលក់ដីក្នុងស្ថានភាពបែបនេះ ក៏មានន័យថាជាការលក់ក្រោមសម្ពាធ ពោលគឺអតិថិជន ត្រូវបង្ខំចិត្តលក់ដោយសារតែរងសម្ពាធ ដែលកើតឡើង ដោយសេចក្តីភ័យខ្លាចថាបើ ពួកគេមិនប្រញាប់លក់ទេ នោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនឹងលក់ដីរបស់ពួកគេ ក្នុងតម្លៃក្រោមទីផ្សារ ឬ ដោយការភ័យខ្លាចថា អាជ្ញាធរមូលដ្ឋាន នឹងកោះហៅទៅសាកសួរ ប្រសិនបើពួកគេមិនមានលទ្ធភាពសងបំណុល។ នៅក្នុងករណីទាំងអស់ដែលស្ថិតក្នុងការស្រាវជ្រាវនេះ គ្មានអតិថិជនណាម្នាក់ចង់លក់ដីរបស់ពួកគេទេ ប៉ុន្តែពួកគេ មិនដឹងថាមានមធ្យោបាយណាផ្សេង ដើម្បីសងបំណុល ក្រៅពីការលក់ដីនោះទេ។

ការដាក់ប្លង់ដីជាទ្រព្យបញ្ចាំ គឺជាការអនុវត្តជាទូទៅ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា។ ប្រជាពលរដ្ឋ ដែលផ្តល់បទសម្ភាសន៍នៅក្នុងការស្រាវជ្រាវនេះ សុទ្ធតែបានដាក់តម្កល់ប្លង់ដីធ្វើជាទ្រព្យបញ្ចាំ ដើម្បីទទួលបានកម្ចី។ ប្លង់ដី ដែលអាចប្រើជាទ្រព្យបញ្ចាំបាន រួមមាន "ប្លង់រឹង" ដែលទទួលស្គាល់ និងចុះបញ្ជីនៅក្នុងស្ថាប័នមានសមត្ថកិច្ចជាតិ និង "ប្លង់ទន់" ដែលបានចុះបញ្ជីតាមរយៈអាជ្ញាធរមូលដ្ឋាន។ បើយោងតាមការសិក្សាលម្អិតទៅលើករណីទាំងអស់នៅក្នុងការស្រាវជ្រាវនេះ រាល់ដីដែលយកធ្វើជា ទ្រព្យបញ្ចាំសុទ្ធតែមានតម្លៃលើសតម្លៃប្រាក់កម្ចី បើទោះជាតម្លៃជាក់ស្តែងនៃដីនៅតំបន់ខ្លះ ក្នុងប្រទេសកម្ពុជា ពិបាកនឹងធ្វើការវាយតម្លៃក្តី។ ផ្អែកតាមការសិក្សាកន្លងមក គេរកឃើញថា ធនាគារអេស៊ីលីដាបានទំលាក់តម្លៃដី ដែលដាក់ជាទ្រព្យបញ្ចាំ នៅក្នុងគោលការណ៍របស់ខ្លួន ពី៥០ ទៅ ៧៥ភាគរយ។ ការកំណត់គោលការណ៍បែបនេះ គឺដើម្បីការពារចំពោះការឡើងចុះនៃតម្លៃដី។[២២]

ទោះជាពិបាកវាយតម្លៃឱ្យច្បាស់លាស់ក្តី ក៏គេអាចប៉ាន់ស្មានបានថាយ៉ាងហោចណាស់ ក៏មានប្លង់ដីប្រមាណ ជាងមួយលានប្លង់ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កំពុងកាន់កាប់ បើតាមការសិក្សាផ្ទៃក្នុងដែលធ្វើ ឡើង ដោយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចេញផ្សាយកាលពីខែ តុលា ឆ្នាំ២០១៧។ របាយការណ៍ ដដែល បានបង្ហាញថា ប្រហែលពាក់កណ្តាល នៃកម្ចីទាំងអស់ គឺមានប្លង់ដីដាក់ជាទ្រព្យបញ្ចាំ[២៣] តែចំនួនជាក់ស្តែង អាចនឹងខ្ពស់ជាងនេះ។ របាយការណ៍នេះបានរកឃើញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន បានអនុវត្តការផ្តល់កម្ចីមិនត្រឹមត្រូវ ដោយតម្រូវឱ្យកូនបំណុលរបស់ខ្លួនដាក់បញ្ចាំប្លង់ដីទាំងអស់ គឺមិនមែនគ្រាន់តែដើម្បី ឱ្យស្មើនឹងតម្លៃនៃប្រាក់

[២២] W. Nathan Green "ពីវាលស្រែក្លាយជាទ្រព្យហិរញ្ញវត្ថុ ដីមានតម្លៃសម្រាប់មីក្រូហិរញ្ញវត្ថុនៅកម្ពុជា" Royal Geographical Society ទំព័រទី៩ ខែមេសា ឆ្នាំ២០១៩

កម្ចីនោះទេ តែដើម្បីរារាំងពួកគេ មិនឱ្យទៅខ្ចីប្រាក់ពី គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត។[២៤] ការសិក្សាស្រាវជ្រាវនេះបាន រកឃើញដូចគ្នានឹងរបាយការណ៍ខាងលើនេះ ដោយអ្នក ផ្តល់បទសម្ភាសន៍សុទ្ធតែបានអះអាងដូចៗគ្នាថា ពួកគេត្រូវតម្កល់ប្លង់ដីលើសពីមួយ ដើម្បីទទួលបានកម្ចីមួយ ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

ការមានប្លង់ដីធ្លីរបស់អតិថិជនក្នុងដៃ ផ្តល់ឥទ្ធិពលដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងការដាក់សម្ពាធដល់អតិថិជន ដើម្បីសងប្រាក់មកវិញ។ ប្រជាពលរដ្ឋដែលផ្តល់បទសម្ភាសន៍ បានរាយការណ៍ថាពួកគេពិតជាមានអារម្មណ៍ថា មានសម្ពាធក្នុងការសងប្រាក់គេវិញឱ្យទាន់ពេលវេលា ព្រោះពួកគេខ្លាចថា បើពួកគេហ៊ានបង់ប្រាក់យឺតតែម្តង នោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នឹងលក់ដីរបស់ពួកគេក្នុងតម្លៃក្រោមទីផ្សារ ដោយមិនចាំបាច់មានការអនុញ្ញាត ពីពួកគេទេ។ អ្នកស្រាវជ្រាវ រកឃើញករណីចំនួនពីរ ដែលទាក់ទងការលក់បែបនេះ ប៉ុន្តែករណីភាគច្រើន គឺពាក់ព័ន្ធនឹងការបង្ខំឱ្យម្ចាស់លក់ដីដោយខ្លួនឯង។

អ្នកស្រាវជ្រាវបានកត់ត្រានូវករណីមួយចំនួន ដែលមន្ត្រីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានគំរាមគំហែងអតិថិជនរបស់ខ្លួនថា នឹងចាត់វិធានការតាមផ្លូវច្បាប់។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តែងតែប្រើវិធីសាស្ត្របែបនេះ តែពួកគេកម្រនឹងប្តឹង កូនបំណុលរបស់ខ្លួនទៅតុលាការណាស់។ ជាញឹកញាប់ នៅពេលអតិថិជនរបស់ពួកគេបង់លុយយឺត ចំនួនពីរឬបីថ្ងៃ មន្ត្រីឥណទានតែងយក "កិច្ចសន្យាច្បាប់ដើម" សំដៅទៅលើកិច្ចព្រមព្រៀងខ្ចីឥណទាន ធ្វើជាសំអាង ហើយអតិថិជនយល់ច្បាស់ណាស់ថានេះ គឺជាការគំរាមកំហែងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលនឹងយកដីពួកគេ លក់ ប្រសិនជាពួកគេមិនអាចសងប្រាក់បាន ។

មានក្នុងករណីមួយពាក់ព័ន្ធ នឹងមន្ត្រីឥណទាន របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់ (Vision Fund) ដែលគ្រឹះស្ថាននេះពីមុនជាផ្នែកមួយ នៃអង្គការទស្សនៈពិភពលោក (World Vision) ដែលជា អង្គការគ្រីស្ទសាសនាអន្តរជាតិ មិនមែនរដ្ឋាភិបាល ក្រោយមកគ្រឹះស្ថាននេះ ត្រូវបានលក់ទៅឱ្យ ធនាគារកូរ៉េខាងត្បូង និង ត្រូវបានប្តូរឈ្មោះ ទៅជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ីហ្វាយនែន នៅពាក់កណ្តាល ឆ្នាំ២០១៨។ មន្ត្រីឥណទាននោះបានបិទផ្លាក "ផ្ទះលក់" នៅមុខផ្ទះ អតិថិជនរបស់ខ្លួន ដោយមិនសុំការអនុញ្ញាតពីម្ចាស់ផ្ទះ ដោយគ្រាន់តែអតិថិជនរូបនោះ ខកខានពុំបានបង់ប្រាក់រយៈពេលប្រាំពីរប្រាំបីថ្ងៃក្រោយពេលកំណត់។ នេះគឺជាក្តីបារម្ភមួយរបស់ អតិថិជន ភាគច្រើន ដែលខ្លាចគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លក់ដីរបស់ពួកគេក្នុងតម្លៃក្រោមទីផ្សារ ដោយមិនមានការអនុញ្ញាតពីពួកគេ ដូចនេះ កាន់តែបន្ថែមសម្ពាធដល់អតិថិជន ឱ្យលក់ដីដោយខ្លួនឯងដើម្បីធានាបាននូវតម្លៃលក់ល្អប្រសើរ។

ជាងនេះទៅទៀត នៅក្នុងករណីជាច្រើន អាជ្ញាធរថ្នាក់ភូមិ-ឃុំបានដើរតួនាទីជា មន្ត្រីអនុវត្តច្បាប់ សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីបង្ខំអតិថិជនឱ្យសងប្រាក់ ឬ បានឆ្លៀតឱកាសកេងចំណេញពីអ្នកភូមិដែលជំពាក់បំណុល តាមរយៈការចងការប្រាក់ឯកជនក្នុងអត្រាការប្រាក់ខ្ពស់ហួសហេតុ។ នៅក្នុងករណីមួយ មេភូមិម្នាក់ដែលមកពីភូមិជិតខាង បានចងការប្រាក់ ឱ្យកូនបំណុលម្នាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយទាមទារ ឱ្យដាក់បញ្ចាំប្លង់ដីចំនួនពីរជាថ្នូរ។ មេភូមិរូបនេះក្រោយមកក៏បានក្លែងបន្លំស្នាមមេដៃរបស់កូនបំណុល និងយកប្លង់ដីទាំងពីរនេះ ទៅលក់ដោយមិនមានការយល់ព្រម ពីកូនបំណុល នៅពេលកូនបំណុលនោះ គ្មានលទ្ធភាពសងប្រាក់។ នៅក្នុងករណីផ្សេងមួយទៀត មានអ្នកភូមិម្នាក់បានរៀបរាប់ថា មេភូមិបានកោះហៅកូនបំណុលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ ដែលបានបង់ប្រាក់យឺតយ៉ាវ ដើម្បីសាកសួរ។ ដោយសារខ្លាចគេកោះហៅ គាត់ក៏បានសម្រេចចិត្តលក់ដី ដើម្បី

## ករណីសិក្សាពីការលក់ដីដោយបង្ខំ

ចំរើន បានខ្ចីប្រាក់ដំបូងពីគ្រឹះស្ថានហិរញ្ញវត្ថុ ហត្ថាកសិករ លីមីធីត ក្នុងឆ្នាំ ២០១០ ដើម្បីសង់ផ្ទះ។ គាត់បានសងប្រាក់កម្ចីវិញអស់ ហើយប៉ុន្មានឆ្នាំក្រោយមកលោក ក៏បានទៅខ្ចីប្រាក់ ៣,០០០ដុល្លារ ដើម្បីដាំម្រេច និងកៅស៊ូ ពីធនាគារ ភូមិ ដែលបានប្តូរឈ្មោះទៅជា អិលអូអិលស៊ី (ខេមបូឌា) នៅឆ្នាំ២០១៥ ខណៈពេលគាត់កំពុងសងប្រាក់ខ្ចី ។

បន្ទាប់ពីខ្ចីបានមួយឆ្នាំ ចំរើនត្រូវបង់សងប្រាក់ដើមតាមកាលកំណត់ ប៉ុន្តែដំណាំរបស់គាត់មិនបានផ្តល់ទិន្នផល។ មន្ត្រីឥណទាននៅ គ្រឹះស្ថាន អិលអូអិលស៊ីបាន ប្រាប់គាត់ឱ្យទៅខ្ចីប្រាក់ឯកជន និងណែនាំគាត់ទៅស្ត្រីម្នាក់ដែលគាត់មិនដែលបានជួបពីមុនមក។ ដំបូងគាត់បានប្រកែក មិនខ្ចីប្រាក់ពីស្ត្រីនោះដោយសារតែអត្រាការ ប្រាក់ខ្ពស់ពេក តែក្រោយមកក៏យល់ព្រមខ្ចីវិញ នៅពេលដែលមន្ត្រីឥណទាននោះបានប្រាប់គាត់ថា អិលអូអិលស៊ីនឹងប្តឹងគាត់ ប្រសិនជាគាត់មិនសងប្រាក់។

ក្នុងរយៈពេលជាង ពីរខែ ចំរើនខំប្រឹងសងបំណុលឯកជននេះទាំងលំបាក ដោយបានបញ្ជូនកូនរបស់គាត់ទៅនៅជាមួយសាច់ញាតិ និងបរិភោគអាហារតិចជាមុនដើម្បីសន្សំប្រាក់។ ទីបំផុតគាត់ក៏បានទៅយកប្រាក់កម្ចីពីហត្ថាកសិករ ដើម្បីសងបំណុលឯកជនមួយភាគធំ និងបានលក់ដីគាត់មួយចំនួនដើម្បីសងផ្តាច់។ គាត់បាន ប្រាប់ទៅមន្ត្រីឥណទានមុនពេលយកកម្ចីថា គាត់នឹងយកប្រាក់កម្ចីនេះទៅសងបំណុលឯកជន តែអ្វីដែលមន្ត្រីឥណទានទាំងនោះខ្វល់ និងចង់បានពីគាត់គឺប្លង់ដី។ ប៉ុន្មានខែក្រោយមក គាត់បានយឺតយ៉ាវក្នុង ការសងប្រាក់ទៅហត្ថាកសិករ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនេះបានទៅរកភាគីទីបីដើម្បីទៅទិញដីពីចំរើន។ ដំបូងគាត់បានប្រកែក តែហត្ថាកសិករបានបញ្ជូនក្រុមការងារ ១១នាក់ មានម៉ូតូបួន និងឡានមួយគ្រឿង ទៅផ្ទះរបស់គាត់ ដើម្បីគំរាមចាត់វិធានការតាមផ្លូវច្បាប់ប្រសិនជាគាត់មិនសងប្រាក់។ ដោយគ្មានជម្រើសផ្សេង ចំរើនក៏បានលក់ដីទៅឱ្យអ្នកទិញនោះ។ ចំរើនបាននិយាយថា "មីក្រូហិរញ្ញវត្ថុមិនបានផ្តល់ប្រយោជន៍អ្វីទេ។ ពីមុនខ្ញុំធ្លាប់មានចំណីអាហារបរិភោគ តែសព្វថ្ងៃនេះជីវភាពខ្ញុំកាន់តែលំបាក ខ្លាំងជាងមុន។"

[២៣] "ការសិក្សាពីភាពជំពាក់បំណុលច្រើនលើសលប់កម្ពុជា ២" ខែតុលា ឆ្នាំ២០១៧

"ប្រសិនជាមានអ្នកវិនិយោគទុនមកទីនេះ សូមធ្វើការសិក្សាស្រាវជ្រាវ ពីផលប៉ះពាល់អវិជ្ជមាន នៃមីក្រូហិរញ្ញវត្ថុផង។ ស្វែងយល់ពីស្ថានភាពកសិករជាមុនសិន មុននឹងធ្វើការវិនិយោគ។ យើងមិនមានប្រាក់គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ជីវភាព និងបង់បំណុលរបស់ពួកយើងទេ។"

ជៀសវៀងពីការបង់ប្រាក់យឺតយ៉ាវ។ មានករណីមួយទៀតកាលពីជិតដប់ឆ្នាំមុន មានមេភូមិម្នាក់បានធ្វើជាមេក្រុម ឱ្យអ្នកយកកម្ចីជាក្រុម សម្រាប់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុប្រាសាក់។ មេភូមិរូបនេះអាចគ្រប់គ្រងអត្រាការប្រាក់ និងអាចរក្សាអំណាច លើអតិថិជនបានតាមរយៈការមិនបង្ហាញអត្តសញ្ញាណ របស់សមាជិកក្រុមផ្សេងទៀត ឬមធ្យោបាយដែលពួកគេទាក់ទង ជាមួយគ្រឹះស្ថាន ដែលផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ។ ចុងក្រោយអតិថិជនដែលជាសមាជិក បានសម្រេចចិត្តលក់ដីដោយសារក្តីបារម្ភថា ពួកគេនឹងបាត់បង់ដីកាន់តែច្រើន ប្រសិនបើពួកគេមិនឆាប់លក់ទេនោះ។

ចរិតលក្ខណៈជាស្ថាប័ន នៃយុទ្ធសាស្ត្រដាក់សម្ពាធទាំងនេះ ត្រូវបានអះអាងដោយ អតីតថ្នាក់ដឹកនាំ និងថ្នាក់ដឹកនាំនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីររូប ដែលបាននិយាយថា មីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ចូលចិត្តប្រើវិធីសាស្ត្របែបនេះ ជាមួយអតិថិជនរបស់ពួកគេ។ ថ្នាក់ដឹកនាំទាំងពីររូបនេះ ធ្លាប់បានកាន់តំណែង ជាច្រើនតាំងពីតំណែងថ្នាក់មធ្យម និងតំណែងកំពូល នៅតាមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្សេងៗ និងមានបទពិសោធន៍ជាង ២០ឆ្នាំ ក្នុងវិស័យនេះ។ ថ្នាក់ដឹកនាំទាំងពីរនេះ ក៏បានអះអាងដូចគ្នាថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតែងតែបង្ខំឱ្យ អតិថិជនរបស់ខ្លួន លក់ដីដើម្បីសងបំណុល។ ម្នាក់ក្នុងចំណោមអ្នកទាំងពីរ បានលើកឡើងថា ដើម្បីរក្សាអត្រាឥណទានមិនដំណើរការឱ្យនៅទាប គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តែងពឹងពាក់លើការលក់ដីរបស់អតិថិជន របស់ខ្លួន និងបាននិយាយថា "តម្លៃដី គឺជាកត្តាសំខាន់តែមួយគត់ សំរាប់ទីផ្សារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបច្ចុប្បន្ន។"

បទសម្ភាសន៍ ជាមួយថ្នាក់ដឹកនាំនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការចុះស្រាវជ្រាវតាមតំបន់គោលដៅ សុទ្ធតែបង្ហាញថា ក្នុងករណីខ្លះ ប្រសិនជា អតិថិជនទទូចមិនព្រមលក់ដី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនឹងស្វែងរកអន្តរាគមន៍ ពីអាជ្ញាធរភូមិ-ឃុំ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនឹងបង់លុយឱ្យមន្រ្តីមូលដ្ឋានទាំងនេះ ឱ្យជួយដាក់សម្ពាធឱ្យអ្នកភូមិសងប្រាក់ជំពាក់មកវិញ។ ថ្នាក់ដឹកនាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានធ្វើសេចក្តីសន្និដ្ឋាន រៀងខ្លួនថាប្រមាណជា១០ភាគរយ នៃបំណុលដែលសងមកវិញ គឺបានតាមរយៈការលក់ដីដោយបង្ខំដោយមានអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋាន។ ពួកគេក៏បានប៉ាន់ស្មានថាចំនួនភាគរយនេះគឺកាន់តែខ្ពស់ជាងនេះទៅទៀត បើនិយាយពីការលក់ដីដោយបង្ខំដែលមិនមានការលូកដៃពីមន្រ្តីថ្នាក់មូលដ្ឋាន។

លទ្ធផលអវិជ្ជមានទាំងនេះ គឺប្រាសចាកពីគោលបំណងរបស់វិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងដៃគូ ផ្តល់មូលនិធិទ្វេភាគី ដែលតែងពោលថា ខ្លួនចង់ធ្វើការងារល្អដល់សង្គម ដោយចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។ លទ្ធផលអវិជ្ជមាន នឹងអូសបន្លាយយូរដោយសារការលក់ដីទាំងនេះ ទាមទារឱ្យមានចំណាត់ការថែមទៀតពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងរដ្ឋាភិបាលដើម្បីធានាថាការលក់ដីដោយបង្ខំនឹងមិនបន្តកើតឡើងតទៅទៀត។



[២៤] ដូចខាងលើ

## ការបាត់បង់ទីលំនៅ

ថ្នាក់ដឹកនាំរបស់មីក្រូហិរញ្ញវត្ថុ បានប្រាប់អ្នកស្រាវជ្រាវឱ្យដឹងថា មន្ត្រីឥណទានកម្របង្ខំអតិថិជនឱ្យលក់លំនៅដ្ឋាន របស់ពួកគេណាស់ ដោយសារមានផលប៉ះពាល់ធ្ងន់ធ្ងរដល់អតិថិជន។ ទោះជាយ៉ាងនេះក្តី អ្នកស្រាវជ្រាវបានរកឃើញករណីចំនួនបួន អំពីការលក់ផ្ទះដើម្បីសងបំណុលមីក្រូឥណទាន។ ក្នុងករណីចំនួនពីរ អ្នកផ្តល់បទសម្ភាសន៍ត្រូវបានប្រាប់ដោយបុគ្គលិករបស់មីក្រូហិរញ្ញវត្ថុឱ្យលក់ផ្ទះរបស់ពួកគេ ដើម្បីជៀសវាងអត្រាការប្រាក់កើនឡើងបន្ថែមនិងថ្លៃពិន័យផ្សេងទៀតដោយសារការសងបំណុលយឺត។ ការបាត់បង់ផ្ទះ ដែលជាលទ្ធផលនៃការខកខានសងបំណុលរបស់ពួកគេបានធ្វើឱ្យគ្រួសារចំនួនបីគ្រួសារ ក្នុងនោះមានមួយគ្រួសារមានក្មេងអាយុ ៣ឆ្នាំ និង ៥ឆ្នាំ ស្ថិតក្នុងភាពទ័លលំបាកខ្លាំង ហើយមិនមានគ្រួសារណាមួយ ក្នុងចំណោមគ្រួសារបីនេះ មានទីជម្រកគ្រប់គ្រាន់ឡើយ រហូតមកដល់ឥឡូវនេះ។



ការបាត់បង់លំនៅដ្ឋាន មិនត្រឹមតែប្រាសចាក ពីគោលបំណងដែលបានលើកឡើងដោយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនោះទេ ថែមទាំងផ្ទុយពីអនុសញ្ញាអន្តរជាតិ ដូចជាកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខា និងធ្វើសច្ចានុម័ត ផងដែរ។ មាត្រា ១១ បានចែងថា រាល់រដ្ឋទាំងអស់ ត្រូវទទួលស្គាល់ពីសិទ្ធិទទួលបានទីលំនៅគ្រប់គ្រាន់ ត្រូវចាត់វិធានការសមស្រប ដើម្បីធានាឱ្យបាននូវសិទ្ធិនេះ។[២៥] មិនមានអតិថិជនរបស់មីក្រូហិរញ្ញវត្ថុ ដែលបានបាត់បង់ផ្ទះសម្បែងណាមួយ ដឹងអំពីការការពារស្របច្បាប់ ឬអំពីអាជ្ញាធរពាក់ព័ន្ធដែលពួកគេអាចពឹងពាក់បានដើម្បីជួយឱ្យរួចផុតពីភាពគ្មានទីជម្រកនោះទេ។

គ្រួសារបីក្នុងចំណោមបួនគ្រួសារ ដែលបានបាត់បង់ផ្ទះបច្ចុប្បន្ននេះ កំពុងប្រឈមនឹង ហានិភ័យនៃភាពគ្មានទីជម្រក។ ខណៈដែលមានគ្រួសារ មួយ បានអនុវត្តសិទ្ធិទទួលបានទីលំនៅរបស់ពួកគេទាន់ពេលវេលា គ្រួសារចំនួនបីទៀតនៅតែងាយរងគ្រោះពីការបណ្តេញចេញគ្រប់ពេល ដោយគ្មានការការពារអ្វីឡើយ។ ទោះជាមានការវិនិយោគធំៗលើលំនៅដ្ឋាន ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះក្តី ស្ទើរតែមិនមានលំនៅដ្ឋានណា ដែលមានតម្លៃសមរម្យសម្រាប់ប្រជាជនក្រីក្រខ្លាំងក្នុងប្រទេសកម្ពុជាឡើយ។

### ករណីសិក្សាពីការបាត់បង់ទីលំនៅ

សម្លឹងទៅកាន់ដីមួយកន្លែង ដែលមានទ្វារបងបិទជិត អ៊ុំទាវបានចង្អុលបង្ហាញពីទីតាំងផ្ទះគាត់ពីមុន។ អស់រយៈពេលជាង ២០ឆ្នាំ គាត់បានរស់នៅក្នុងផ្ទះដែល ស្ថិតនៅក្រោមម្លប់ដើមស្វាយ ជាផ្ទះដែលកូនស្រីនិងកូនប្រុសរបស់គាត់ធំធាត់ឡើង។ ប៉ុន្តែក្នុងពេលនេះ ស្ថិតក្នុងវ័យ ៦០ឆ្នាំ ដីគាត់ពីមុនត្រូវបានទុកចោល ហើយផ្ទះគាត់ត្រូវបានកំទេច ចោលក្រោយពេលគាត់លក់ផ្ទះនោះដើម្បីយកប្រាក់ទៅសងបំណុលមីក្រូហិរញ្ញវត្ថុ។

អ៊ុំទាវបានយកប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដៃគូ ដើម្បីទិញចំណីអាហារ ទឹកដោះគោ និងថ្នាំពេទ្យសម្រាប់ចៅៗរបស់គាត់។ ឪពុកម្តាយរបស់ក្មេងទាំងនោះបានធ្វើចំណាកស្រុក ដើម្បីរកការងារធ្វើ ប៉ុន្តែប្រាក់ ដែលពួកគេផ្ញើមកឱ្យ មិនគ្រាន់សម្រាប់សងប្រាក់កម្ចីនោះទេ។ អស់រយៈពេលបីឆ្នាំ មន្ត្រីរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតែងតែមកប្រាប់គាត់ ឱ្យសងប្រាក់កម្ចីវិញ ហើយអ៊ុំទាវតែងតែប្រាប់ទៅវិញថា គាត់ពុំមានលទ្ធភាពចិញ្ចឹមចៅៗរបស់គាត់ និងសងប្រាក់កម្ចីនោះ ទេ។ គាត់បានរៀបរាប់ប្រាប់ថា មានពេលមួយនោះ មន្ត្រីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានផ្តល់ដំណោះស្រាយមួយទៅគាត់។ មន្ត្រីទាំងនោះបានប្រាប់គាត់ “អ៊ុំគួរតែទៅរកការងារធ្វើ ហើយយកចៅៗទៅដាក់នៅមណ្ឌលកុមារកំព្រា។"

បំណុលដើមរបស់គាត់មានចំនួន ៥,០០០ដុល្លារ ហើយប្រាក់ពិន័យសម្រាប់ការសងយឺតដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឱ្យគាត់បង់មានចំនួនជាង ៣,០០០ដុល្លារ សរុបទៅបំណុលគាត់កើនដល់ ៨,០០០ដុល្លារ។ ដោយសារមានការ ជម្រុញពីមន្ត្រីឥណទាន អ៊ុំទាវបានលក់ផ្ទះរបស់គាត់ក្នុងតម្លៃ ៩,០០០ ហើយបានយកប្រាក់នេះទៅទូទាត់សងបំណុលជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអស់ស្ទើរតែគ្មានសល់ប្រាក់បន្តិចបន្តួចសោះ។

អ៊ុំទាវសព្វថ្ងៃរស់នៅជាមួយចៅពីរនាក់របស់គាត់ដែលមានអាយុ ៣ឆ្នាំ និង ៤ឆ្នាំ ក្នុងខ្ទមស័ង្កសីនៅលើដីរបស់រដ្ឋ។ អ្នកជិតខាងគាត់ បានឱ្យប្រាក់ ដើម្បីសង់ខ្ទម ហើយមេភូមិបានអនុញ្ញាតឱ្យគាត់ប្រើប្រាស់ដីនោះ។ ទោះជាយ៉ាងនេះក្តីកម្រិតជីវភាពរបស់គាត់បានធ្លាក់ចុះយ៉ាងសម្បើម។ គាត់ងាយនឹងរងគ្រោះពីការបណ្តេញចេញដោយមិនមានការប្រាប់ឱ្យដឹងមុន។ នេះគឺជាបញ្ហាដែលគាត់គិតក្នុងចិត្ត ហើយព្រួយបារម្ភខ្លាំង។ អ៊ុំទាវបានប្រាប់ថាផ្ទះថ្មីរបស់គាត់ក្តៅខ្លាំងនៅពេលថ្ងៃដោយសារមានដំបូលស័ង្កសី និងខ្វះដើមឈើ ប៉ុន្តែគាត់មិនមានកន្លែងផ្សេងទៀតដែលអាចទៅបាន ម៉្យាងត្រូវនៅមើលថែទាំចៅៗរបស់គាត់។

អ៊ុំទាវបាននិយាយប្រាប់អ្នកស្រាវជ្រាវ "ខ្ញុំនៅតែទៅអង្គុយក្បែរផ្ទះចាស់របស់ខ្ញុំព្រោះវាមានម្លប់ ហើយខ្ញុំនឹកផ្ទះរបស់ខ្ញុំ។ ខ្ញុំនឹកពេលដែលខ្ញុំនិយាយគ្នាលេងជាមួយមិត្តខ្ញុំនៅទីនោះ។"

[២៥] មាត្រា ១១ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ ឆ្នាំ១៩៦៦ ។

## ពលកម្មកុមារ

ពលរដ្ឋជាច្រើនគ្រួសារ ដែលមានការពិបាក ក្នុងការសងបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តែងតែប្រើប្រាស់កុមារ ដើម្បីជួយធ្វើការងាររកប្រាក់កម្រៃ និងធ្វើឱ្យកុមារបាត់បង់ឱកាសចូលសាលារៀនដោយការទៅធ្វើការស៊ីឈ្នួលក្នុងចំការ ឬធ្វើចំណាកស្រុកដើម្បីរកការងារធ្វើបានប្រាក់ចំណូលជួយជីវភាពគ្រួសារ។ ពលរដ្ឋចំនួន ១៣គ្រួសារក្នុងចំណោមពលរដ្ឋចំនួន ២៨គ្រួសារ ដែលត្រូវបានសម្ភាស និយាយថា បានឱ្យកុមារធ្វើការងាររកប្រាក់ ដើម្បីអាចសងបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ភាគច្រើននៃកុមារ ដែលធ្វើការងាររកប្រាក់ទាំងនោះមានអាយុពី ១៣ ទៅ ១៧ឆ្នាំ (អ្នកស្រាវជ្រាវបានដឹងអំពីករណីមួយចំនួន ដែលមានកុមារជួយធ្វើការងាររកប្រាក់ មានអាយុត្រឹម ៧ឆ្នាំ ដោយត្រូវបានឪពុកម្ដាយឱ្យជួយធ្វើការងារក្នុងចំការផ្ទាល់ខ្លួន ដើម្បីរកប្រាក់ជួយដោះបំណុល)។

ករណីនៃពលកម្មកុមារ អាចត្រូវបានរាប់បញ្ចូល នៅក្នុងការស្រាវជ្រាវនេះ តែក្នុងករណី ដែលអ្នកត្រូវបានសម្ភាសន៍រាយការណ៍ថាបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាកត្តាចំបង ដែលជំរុញឱ្យកុមារធ្វើការងាររកប្រាក់ ដើម្បីដោះបំណុលនោះ។ ករណីជាច្រើនដែលពាក់ព័ន្ធនឹង ក្មេងជំទង់អាយុពី ១៥ ដល់ ១៧ឆ្នាំ ដែលផ្លាស់ទៅរស់នៅទីក្រុង ដោយក្មេងប្រុសតែងតែទៅធ្វើការងារសំណង់ រីឯក្មេងស្រីតែងតែទៅធ្វើការងារជាអ្នកបម្រើការងារតាមផ្ទះ។ ការងារនេះអាចមានហានិភ័យ និងធ្វើឱ្យកុមារងាយរងគ្រោះពីអំពីជួញដូរ រងរបួស ឬកេងប្រវ័ញ្ច។ អ្នកត្រូវបានសម្ភាសជាច្រើន បង្ហាញអារម្មណ៍សោកស្ដាយ ដែលគិតថាវាសំខាន់ក្នុងការឱ្យកុមារជួយធ្វើការងាររកប្រាក់កម្រៃ។ អ្នកទាំងនោះ បង្ហាញអារម្មណ៍ ចង់បញ្ជូនកូនៗរបស់ពួកគេត្រឡប់ចូលសាលារៀនវិញ។ ប៉ុន្តែ ពួកគេមិនមានលទ្ធភាពធ្វើបែបនេះ ព្រោះការឱ្យកូនៗជួយ ធ្វើការងារ គឺជាតម្រូវការរបស់មន្ត្រីឥណទាននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ បន្ទុកមួយបន្ថែមទៀត សម្រាប់ឪពុកម្ដាយគឺជាការចំណាយ ក្នុងការឱ្យកូនៗរបស់ពួកគេ បានចូលរៀនដែលធ្វើឱ្យឪពុកម្ដាយទាំងនោះសម្រេចចិត្ត មិនបញ្ជូនកូនទៅរៀន។ ករណីទូទៅជាច្រើន នៃពលកម្មកុមារ រួមមានការឱ្យកុមារឈប់រៀនដើម្បីជួយធ្វើការងារក្នុងចំការផ្ទាល់ខ្លួន ដើម្បីសន្សំប្រាក់ពីការជួលកម្មករពីខាងក្រៅ ឬដើម្បីឱ្យឪពុកម្ដាយអាចទៅធ្វើការងារផ្សេង បង្កើនចំណូលក្នុងគ្រួសារ។

### ករណីសិក្សាអំពីពលកម្មកុមារ

វ៉ាន់ ឌី ជាមនុស្សរួសរាយរាក់ទាក់ ហើយញញឹមស្រស់។ លោក និយាយលេង នៅពេលលោកទាញក្រដាសលក្ខខណ្ឌកម្ចីទាំងប្រាំពីររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅមុខលោក។ ប៉ុន្តែអាកប្បកិរិយាសុទិដ្ឋិនិយមរបស់លាក បានរសាត់បាត់ នៅពេលដែលលោក ចាប់ផ្ដើមរៀបរាប់ពីការធ្លាក់ចូលក្នុងអន្ទាក់បំណុលរបស់លោក ហើយនិងស្ថានភាពដែលលោកឱ្យកូនលោកទាំងប្រាំមួយជួយធ្វើការងារ និងរកប្រាក់ដើម្បីជីវភាព។

ជីវភាពរបស់លោកចាប់ផ្ដើមពីបំណុលបន្តិចបន្តួច ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជា (AMK) ដើម្បីយកមកធ្វើស្រែចំការ។ ខណៈពេលដែល លោកកំពុងសងបំណុល លោកចាប់ផ្ដើមខ្ចីប្រាក់ក្នុងចំនួនច្រើនពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករលីមីតធីត (HKL) និងវីសិនហ្វាន់ ដើម្បីដាំដំឡូង។ ក្រោយមកប្រហែល មួយខែក្រោយពីទទួលបានប្លង់ដី ពីក្រុមស្ម័គ្រចិត្តរបស់សម្ដេចនាយករដ្ឋមន្ត្រី លោក បានប្រើប្រាស់ប្លង់នោះ ដើម្បីទទួលបានកម្ចីថ្មីទៀត ហើយបន្ទាប់មកលោកខ្ចីលុយពីអ្នកចងការប្រាក់ឯកជន ដើម្បីដោះបំណុលទាំងនោះ។ ភ្លាមៗក្រោយមក លោក វ៉ាន់ឌី ជំពាក់បំណុល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រេឌីត ចំនួន ១ម៉ឺន ដុល្លារអាមេរិក។ លោក មិនដែលបានឃើញប្លង់ដីទាំងបួនរបស់លោកអស់ជាច្រើនឆ្នាំ។

លោក បានលក់ដីស្រែចំនួន ២,៩ ហិកតា ដើម្បីដោះបំណុលចំនួន ១ ម៉ឺនដុល្លារ ហើយនិងដោះបំណុលមួយចំនួនរបស់អ្នកចងការប្រាក់ឯកជន។ មេភូមិរបស់លោក ណែនាំលោក ឱ្យទាក់ទងនឹងអ្នកចងការប្រាក់ឯកជន ដើម្បីខ្ចីប្រាក់យកមកផ្គត់ផ្គង់ជីវភាព និងដោះបំណុលផ្សេងទៀត។ ប៉ុន្តែអត្រាការប្រាក់ខ្ពស់ហួសហេតុធ្វើឱ្យលោកមិនមានលទ្ធភាពដោះបំណុលនោះ និងចិញ្ចឹមកូនលោកបានទេ។

នៅឆ្នាំ ២០១៨ វ៉ាន់ឌី បានខ្ចីប្រាក់ពីធនាគារ អេស៊ីលីដា ហើយក្រោយមកលោកមិនអាចសងបំណុលនេះបាន។ មន្ត្រីឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រេឌីតបានប្រាប់លោក ថា លោកអាចខ្ចីប្រាក់ពីគ្រឹះស្ថាន ក្រេឌីត ដើម្បីយកទៅសងបំណុលនៅធនាគារ អេស៊ីលីដា បាន ហើយលោកក៏ធ្វើតាម។ កូនៗរបស់លោកដែលមានអាយុ ១០ឆ្នាំ ១៣ឆ្នាំ និង១៥ឆ្នាំ បានចាប់ផ្ដើមជួយលោកដាំ និងប្រមូលផលស្វាយចន្ទី នៅខណៈដែលកូនស្រីពីរនាក់របស់លោកដែលមានអាយុ ១៥ និង ១៦ឆ្នាំ បានចំណាកស្រុកតាមរយៈមេអណ្ដើក ទៅធ្វើការជាអ្នកបម្រើតាមផ្ទះនៅរាជធានីភ្នំពេញ។ កូនស្រីអាយុ ១៥ឆ្នាំ បានត្រឡប់មកផ្ទះវិញ ពីរបីខែក្រោយមក ព្រោះការងារលំបា កខ្លាំងពេក រីឯកូនស្រីអាយុ ១៦ឆ្នាំ ត្រូវបានម្ចាស់ផ្ទះដេញចេញពីផ្ទះទាំងកណ្ដាលយប់ ហើយត្រូវបានជួយសង្គ្រោះដោយបងប្អូនដែលរស់នៅភ្នំពេញ។ វ៉ាន់ ឌី ធ្លាក់ខ្លួនឈឺ និងព្រួយបារម្ភពីកូនស្រីរបស់លោក ប៉ុន្តែលោកមានអារម្មណ៍ថាលោកគ្មានជម្រើសអ្វីផ្សេងពីនេះ ដើម្បីដោះបំណុលពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនោះទេ។



## ការចំណាកស្រុក

ការធ្វើចំណាកស្រុក រួមទាំងចំណាកស្រុករបស់កុមារអាយុក្រោម ១៨ឆ្នាំ កើតមានជារឿយៗនៅក្នុងគ្រួសារ ដែលជាប់បំណុលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គ្រួសារចំនួន ១៨ ក្នុងចំណោមគ្រួសារទាំង ២៨ ដែលត្រូវបានសម្ភាស មានសមាជិកធ្វើចំណាកស្រុកដើម្បីរកការងារធ្វើបង្កើនចំណូលគ្រួសារ ដើម្បីជួយដោះបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

បញ្ហា ដែលកំពុងកើតមានឡើងនេះ ត្រូវបានលើកឡើងម្តងរួចហើយនៅក្នុងរបាយការណ៍ឆ្នាំ២០១៦ របស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ដោយបានរកឃើញថា៤០,៦ភាគរយ នៃជន ចំណាកស្រុកកម្ពុជាបានចាកចេញពីប្រទេស ដោយសារ ជំពាក់បំណុល ហិរញ្ញវត្ថុក្នុងប្រទេស។[២៦] លើសពីនេះ របាយការណ៍កាលពីខែសីហា ឆ្នាំ២០១៧ ដែលត្រូវបានចេញផ្សាយដោយការិយាល័យ អង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការគ្រឿងញៀន និងបទល្មើសព្រហ្មទណ្ឌ បានកត់សម្គាល់ អំពីទំនាក់ ទំនង រវាងការជាប់បំណុល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការធ្វើចំណាកស្រុក ដោយបានលើកឡើងថា "សម្រាប់ពលរដ្ឋកម្ពុជាជាច្រើន បំណុលគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ តែងតែមិនអាចជួយសម្រាលបន្ទុកលើបញ្ហា ហិរញ្ញវត្ថុនោះទេ។ ផ្ទុយទៅវិញបំណុលទាំងនោះ បែរជារុញច្រានឱ្យអ្នកខ្ចីធ្លាក់ខ្លួនកាន់តែជ្រៅ ទៅក្នុងភាពក្រីក្រ"។[២៧] របាយការណ៍នេះ ក៏បានកត់សម្គាល់ថា "ទំនាក់ទំនងរវាងបំណុល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចំណាកស្រុក និង ការជួញដូរមនុស្ស គឺមិនត្រូវបានគេចងក្រង ឱ្យបានត្រឹមត្រូវ ឬធ្វើការស្រាវជ្រាវនៅឡើយទេ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ និងវិភាគទៅថ្ងៃមុខ"។

អ្នកស្រាវជ្រាវជាច្រើន ដែលបានធ្វើការសិក្សាលើករណីនេះ បាននិយាយជាមួយសមាជិកក្រុមគ្រួសារដែលបានរាយការណ៍អំពីការទទួលរងនូវការរំលោភបំពានរបស់បងប្អូនរបស់អ្នកទាំងនោះ ដែលជាអ្នកបានទៅធ្វើការងារ ដោយចំណាកស្រុក។ អ្នកចំណាកស្រុកទាំងនោះជាទូទៅតែងបង្ហាញអារម្មណ៍សោកស្តាយ ដែលគិតថាចំណាកស្រុកអាចជួយដោះបំណុលរបស់អ្នកទាំងនោះ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបាន។ នៅក្នុងករណីមួយ ក្មេងស្រីម្នាក់ដែលមិនទាន់គ្រប់អាយុត្រូវបានគេដេញចេញពីផ្ទះ នៅរាជធានីភ្នំពេញទាំងកណ្តាលយប់ នៅ

## ករណីសិក្សានៃការធ្វើចំណាកស្រុក

ដំបូង សារ័ត្នបានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេអឹមខេ (AMK) ដើម្បីសង់ផ្ទះ។ នាងបានខ្ចីប្រាក់យ៉ាងច្រើនពីគ្រឹះស្ថាននេះ ហើយក្រោយមកបានខ្ចីប្រាក់ពីគ្រឹះស្ថានធនាគារភូមិ និងវីសិនហ្វាន់ (VisionFund) ដើម្បីយកជាដើមទុនធ្វើចំការតូចមួយរបស់នាង។ នាង ក៏បានខ្ចីប្រាក់ក្រៅផ្លូវការមួយចំនួន ដើម្បីបង្វិលសងបំណុលចាស់របស់ គ្រឹះស្ថានទាំងនោះវិញ ដើម្បីឱ្យអាចខ្ចីប្រាក់បានច្រើនជាងមុនពីគ្រឹះស្ថានទាំងនោះ។ នៅពេលដែលបំណុលរបស់នាងកាន់តែច្រើនឡើងៗលើសពីចំនូលរបស់នាង នាងក៏សម្រេចចិត្តខ្ចីប្រាក់ពីធនាគារ អេស៊ីលីដា តែមួយ ដើម្បីដោះបំណុលតូចផ្សេងៗទៀត ដោយដាក់បញ្ចាំប្លង់ដីចំការរបស់នាង ហើយនាងបានធ្វើចំណាកស្រុកទៅប្រទេសថៃ ជាមួយស្វាមីរបស់នាង ដើម្បីរកប្រាក់ដោះបំណុលនៅធនាគារនោះ។ នាងបាននិយាយថា៖ "នៅទីនេះ [កម្ពុជា] មិនមានការងារធ្វើនោះទេ"។

សារ័ត្ន បានសងបំណុលរប ស់នាងពីធនាគារ អេស៊ីលីដា តាមរយៈការធ្វើការងារនៅប្រទេសថៃជារៀងរាល់ខែ ហើយការសងមិនដែលឱ្យមានការយឺតយាវនោះទេ។ ទោះបីជាយ៉ាងនេះ ក្តី នាងនិយាយថា មន្ត្រីឥណទាន ចាប់ផ្តើមសួរទៅអ្នកជិតខាងនាង និងបងប្អូននាងនៅស្រុកកំណើតថា ហេតុអ្វីបានជាមិនឃើញនាងនៅក្នុងភូមិ។ នាង សង្ស័យថា អ្នកទាំងនោះបារម្ភថានាងនឹងមិនត្រឡប់ទៅផ្ទះនាងវិញ ដោយសារកូនៗរបស់នាងទាំងប្រាំ ក៏មិននៅក្នុងភូមិដែរ។ នៅខណៈពេលដែលនាងមិនបានដឹងច្បាស់លាស់ សារ័ត្នត្រឡប់មកផ្ទះវិញពីរបីឆ្នាំមុន ហើយបានដឹងថាធនាគារ បានរៀបចំលក់ដីចំការរបស់នាងទៅឱ្យអ្នកទិញ-លក់ដីដែលមានទ្រព្យម្នាក់មកពី ខា ងក្រៅភូមិ។ នាង សង្ស័យថាអ្នកទាំងនោះបានសហការជាមួយអាជ្ញាធរ ដើម្បីក្លែងស្នាមមេដៃរបស់នាងលើកិច្ចសន្យាលក់ ដែលនាងមិនដែលបានឃើញសោះ។ អ្វីដែលធនាគារប្រាប់នាង នៅពេលដែលនាងបានត្រឡប់មកផ្ទះវិញ គឺថាដីរបស់នាង ត្រូវបានគេលក់ ហើយបំណុលរបស់នាងត្រូវបានគេដោះរួចរាល់។

សារ័ត្ន រស់នៅក្នុងខ្ទមមួយជាមួយកូនទាំងប្រាំរបស់នាង។ កូនច្បង ដែលមានអាយុ ១៤ ឆ្នាំ ជួយទៅស៊ីឈ្នួលធ្វើការងារក្នុងចំការស្វាយចន្ទី នៅក្នុងភូមិជារៀងរាល់ថ្ងៃ ដើម្បីជួយសងបំណុលក្រៅផ្លូវការដែលនាងបានបង្ខំចិត្តខ្ចី ដើម្បីចិញ្ចឹមជីវិតរបស់នាង ក្រោយពេលដែលធនាគារបានលួចលក់ដីរបស់នាង។ កូនស្រីបន្ទាប់របស់នាង កំពុងមានជំងឺ តែនាងមិនហ៊ានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៀតទេ។ នាងខ្លាចថាគ្រឹះស្ថានទាំងនោះនឹងលក់ផ្ទះរបស់នាងទៀត ដែលជាទ្រព្យនាងនៅសល់តែមួយគត់។ នាងបាននិយាយថា "គ្រឹះស្ថាន/ធនាគារទាំងនោះ មិនខ្វល់ទេ។ គេខ្វល់តែលុយរបស់គេប៉ុណ្ណោះ"។

---

[២៦] "របាយការណ៍វាយតម្លៃស្ថានភាពនៃកម្មករចំណាកស្រុកកម្ពុជាដែលបានធ្វើមាតុភូមិនិវត្តន៍" អង្គការអន្តរជាតិទេសន្តរប្រវេសន៍កម្ពុជា (IOM) ទំព័រទី១៤ ឆ្នាំ ២០១៦ អាចទាញយកបានតាមរយៈ៖ https://www.iom.int/sites/default/files/country/docs/IOM-AssessmentReportReturnedMigrants2016.pdf.

[២៧] "ការជួញដូរមនុស្សពីកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ទៅកាន់ប្រទេសថៃ" ការិយាល័យនៃអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងបទល្មើសព្រហ្មទណ្ឌ ទំព័រទី១៨ ខែសីហា ឆ្នាំ២០១៧ អាចទាញយកបានតាមរយៈ៖ https://www.unodc.org/documents/southeastasiaandpacific//Publications/2017/Trafficking_in_persons_to_Thailand_report.pdf.

ពេលដែលនាងកំពុងធ្វើការងារជាអ្នកបម្រើតាមផ្ទះ។ ករណីមួយទៀត ម្តាយម្នាក់របស់ក្មេង ដែលមានអាយុ ៣ និង៥ឆ្នាំ បានទៅធ្វើការងារជាអ្នកបម្រើតាមផ្ទះនៅប្រទេសសិង្ហបុរី។ នៅក្នុងករណីមួយផ្សេងទៀត ម្តាយរបស់ក្មេងតូចៗមួយចំនួន បានធ្វើការចំណាកស្រុកទៅធ្វើការងារ នៅប្រទេសថៃ ជាមួយស្វាមីរបស់អ្នកស្រី ដើម្បីរកប្រាក់ដោះបំណុលរបស់អ្នកទាំងនោះ ជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៉ុន្តែនៅពេលដែល គ្រឹះស្ថាននោះដឹងថានាងមិននៅក្នុងភូមិ គ្រឹះស្ថាននោះ បានលក់ដីធ្លីរបស់នាងដោយមិនមានការយល់ព្រមពីនាង ទោះជានាងមិនដែលយឺតយ៉ាវក្នុងការសងបំណុលក៏ដោយ។

អ្នកស្រាវជ្រាវម្នាក់ក្នុងចំណោមអ្នកស្រាវជ្រាវជាច្រើន អ្នកស្រី Mary-ann Bylander ដែលបានចេញផ្សាយនូវរបាយការណ៍ជាច្រើន ដែលបង្ហាញពីទំនាក់ទំនង រវាងបំណុលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងចំណាកស្រុកនៅប្រទេសកម្ពុជា។ អ្នកស្រី បានសរសេរកាលពីឆ្នាំ ២០១៨ថា៖

"នៅខណៈដែល មានការបង្ហាញតិចតួចថាជនចំណាកស្រុក ជាហានិភ័យហិរញ្ញវត្ថុសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ យើងនៅតែដឹងថាបំណុល បង្កើនភាពងាយរងគ្រោះដល់កម្មករចំណាកស្រុក។ ទោះជាមានការលើកទឹកចិត្តខ្លាំង ឱ្យពលរដ្ឋសងបំណុលនៅក្នុងស្រុកក៏ដោយ ក៏អ្នកទាំងនោះ នៅតែចំណាកស្រុកដើម្បីរកប្រាក់ដោះបំណុល។ ការជាប់ជំពាក់នឹងបំណុល ត្រូវបានរកឃើញថាជាបញ្ហាបណ្តាលឱ្យកម្មករចំណាកស្រុកទៅធ្វើការងារដែលមានលក្ខណៈកេងប្រវ័ញ្ច ដែលធ្វើឱ្យអ្នកទាំងនោះពិបាកចាកចេញពីការងារដែលមានស្ថានភាពអាក្រក់ បណ្តាលឱ្យមានការព្រួយបារម្ភ និងបាក់ទឹកចិត្ត។ នេះអាចធ្វើឱ្យអ្នកទាំងនោះ ងាយធ្លាក់ចូលទៅក្នុងការងារធ្វើការដោយបង្ខំ និងបង្ខំឱ្យពួកគេរត់ចេញពីការអនុវត្តតាមកិច្ចសន្យាការងារ ដែលបណ្តាលឱ្យពួកគេបាត់បង់ស្ថានភាពស្របច្បាប់នៅក្នុងប្រទេសដែលពួកគេធ្វើការងារនោះ"។[២៨]

នៅឆ្នាំ ២០១៨ អង្គការសមាគមធាងត្នោត បានធ្វើការស្រាវជ្រាវមួយទៅលើសហគមន៍មួយចំនួន ដែលទើបតែផ្លាស់លំនៅមករាជធានីភ្នំពេញ។ ករណីមួយចំនួន ពលរដ្ឋជាច្រើនគ្រួសារ បានមករស់នៅទីក្រុង ដើម្បីគេចចេញពីមន្ត្រីឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនោះ និង ស្វែងរកប្រាក់ចំណូលដើម្បីសងបំណុលរបស់ពួកគេ។ សហគមន៍មួយចំនួនក្នុងចំណោមសហគមន៍ទាំងនោះ បានមករស់នៅលើដីរបស់រដ្ឋដោយខុសច្បាប់ ដែលធ្វើឱ្យអ្នកទាំងនោះស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់នៃការបណ្តេញចេញ និងរស់នៅក្នុងស្ថានភាពលំបាកខ្លាំងដើម្បីព្យាយាមរកប្រាក់ចំណូល។

[២៨] Maryann Bylander, "ផលប៉ះពាល់ធំទូលាយនៃឥណទានខ្នាតតូច៖ ការជាប់ផុងធ្ងន់ធ្ងន់ក្នុងវិបត្តិបំណុល និងចំណាកស្រុកឆ្លងប្រទេស", American Sociological Association, ទំព័រទី២ ឆ្នាំ២០១៨ អាចទាញយកបានតាមរយៈ៖ https://sociologyofdevelopment.files.wordpress.com/2018/03/3_2_bylander.pdf.

## ការបញ្ចាំខ្លួនដោះបំណុល

កម្រិតបំណុលខ្ពស់ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានឯកជនបានធ្វើឱ្យពលរដ្ឋកម្ពុជា រាប់ពាន់នាក់ធ្លាក់ក្នុងវិបត្តិ នៃការធ្វើការងារដើម្បីដោះបំណុល ឬបញ្ចាំខ្លួនដោះបំណុល នៅក្នុងសិប្បកម្មឡឥដ្ឋ នៅក្នុងប្រទេស។ អង្គការ លីកាដូ បានចេញផ្សាយនូវរបាយការណ៍ កាលពីខែធ្នូ ឆ្នាំ២០១៦ ស្តីពី "ការអភិវឌ្ឍលើទាសភាព៖ ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារ ក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា" ដែលបានបង្ហាញយ៉ាងលំអិត អំពីអំពើល្មើសផ្នែកព្រហ្មទណ្ឌ និងការរំលោភបំពានរបស់សិប្បកម្មឡឥដ្ឋទាំងនោះ ហើយនិងការប្រើប្រាស់ ចំណងនៃបំណុលរបស់ខ្លួនលើកម្មករ។ របាយការណ៍នេះ ក៏បានបង្ហាញអំពីហានិភ័យធ្ងន់ធ្ងរទៅលើសុខភាពរបស់កម្មករ ដែលធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋ។ ភាគច្រើននៃកម្មករទាំងនេះ ជាប់ជំពាក់បំណុលជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬ "ភ្នាក់ងារឥណទានក្នុងភូមិ" (អង្គការមិនមែនរដ្ឋាភិបាលចុះបញ្ជី ដែលផ្តល់ឥណទានខ្នាតតូច ប៉ុន្តែមិនមានលក្ខខណ្ឌ ដើម្បីទទួលបានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ)។ ចាប់តាំងពីចេញផ្សាយនូវរបាយការណ៍នេះ រាជរដ្ឋាភិបាល មិនទាន់ចាត់វិធានការ ដើម្បីបញ្ឈប់ឱ្យមានការបញ្ចាំខ្លួនដើម្បីដោះបំណុលនៅក្នុងសិប្បកម្មឡឥដ្ឋនោះទេ។ របាយការណ៍មួយរបស់អ្នកស្រាវជ្រាវជនជាតិអង់គ្លេស ដែលចេញផ្សាយក្រោយរបាយការណ៍អង្គការ លីកាដូ ក៏បានរកឃើញថា បំណុលដើមរបស់កម្មករដែលបានបញ្ចាំខ្លួនដើម្បីដោះបំណុលជាច្រើន គឺជាបំណុលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។[២៩] ករណីមួយ ដែលត្រូវបានលើកឡើងដោយអ្នកស្រាវជ្រាវមួយចំនួនកាលពីឆ្នាំ ២០១៤ បានរកឃើញថា គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុមួយបានតម្រូវឱ្យ អនីតិជនជាប់កាតព្វកិច្ចក្នុង កិច្ចសន្យា ក្នុងការធ្វើការងារដើម្បីដោះបំណុលរបស់ម្តាយនាង។[៣០] ទោះបីជាការបញ្ចាំខ្លួនដោះបំណុលរំលោភ នឹងអនុសញ្ញារបស់អង្គការ សហប្រជាជាតិ ស្តីពីការលុបបំបាត់អំពើទាសភាព[៣១] និងអនុសញ្ញាលេខ ២៩ របស់អង្គការពលកម្មអន្តរជាតិស្តីពីការធ្វើការងារដោយបង្ខំ[៣២] ក៏អំពើនេះ នៅតែមានច្រើន ហើយជាពិសេសនៅក្នុងវិស័យសិប្បកម្មឡឥដ្ឋ ក្នុងប្រទេសកម្ពុជា ដែលអំពើនេះតែងតែបណ្តាលមកពីការជាប់បំណុលពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

## ករណីសិក្សាអំពីការបញ្ចាំខ្លួនដោះបំណុល

នៅខែមីនា ឆ្នាំ២០១៩ កុមារីម្នាក់ដែលមានអាយុ ៩ឆ្នាំ បានដាច់ដៃក្រោយ ពីដៃនាងបានជាប់ចូលទៅក្នុងម៉ាស៊ីនកាត់ឥដ្ឋ ក្នុងពេលធ្វើការងារនៅក្នុងសិប្បកម្មឡឥដ្ឋមួយ នៅខេត្តកណ្តាល។ ក្រុមគ្រួសាររបស់នាងបានជាប់ជំពាក់ នឹងបំណុលជាមួយម្ចាស់សិប្បកម្មឡ ឥដ្ឋបន្ទាប់ ពីគ្រួសារនាងមិនអាចដោះបំណុល ចំនួន ២.០០០ដុល្លារអាមេរិក ពីធនាគារភូមិ (ធនាគារនេះបច្ចុប្បន្នមានឈ្មោះថា LOLC បន្ទាប់ពីត្រូវបានគេទិញកាលពីឆ្នាំ ២០១៤)។

អ្នកទាំងនោះមិនមានលទ្ធភាពសងបំណុល ក្រោយពេលដែលជីដូនរបស់កុមារីធ្លាក់ខ្លួនឈឺ ដោយមិនមានលទ្ធភាពសងបំណុល ដែលនៅសល់ជាង ១០០ ដុល្លារ ក្នុងមួយខែនោះទេ។ មន្ត្រីឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានប្រាប់ ក្រុមគ្រួសារកុមារីនោះថា ប្រសិនបើ អ្នកទាំងនោះមិនអាចសងបំណុល បានទេនៅក្នុងរយៈពេលបីខែ អ្នកទាំងនោះត្រូវយកដីធ្លីរបស់ពួកគេ ទៅដាក់បញ្ចាំ (ដីធ្លីនោះជាដីលំនៅស្ថាន តែមួយគត់របស់ក្រុមគ្រួសារនាង នៅពេលនោះ) ដើម្បីធានាដល់ការសងបំណុល។

ដើម្បីជៀសពីការបាត់បង់ដី និងផ្ទះ សមាជិកទាំង ១២នាក់ ក្នុងគ្រួសារនាង បានបញ្ចាំខ្លួនដើម្បីដោះបំណុល នៅក្នុងសិប្បកម្មឡឥដ្ឋមួយក្បែររាជធានីភ្នំពេញ ដោយដំបូងយកប្រាក់ឈ្នួលពីការធ្វើការងារក្នុងសិប្បកម្មឡឥដ្ឋរបស់អ្នកទាំងនោះ ទៅសងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ បន្ទាប់មកអ្នកទាំងនោះ បានខ្ចីប្រាក់យ៉ាងច្រើនពីសិប្បកម្មឡឥដ្ឋ ដើម្បីដោះបំណុល ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលធ្វើឱ្យអ្នកទាំងនោះ ជាប់ខ្លួនក្នុងបំណុលជាមួយ សិប្បកម្មឡឥដ្ឋ។ កូនៗដែលមានវ័យតិចជាងគេ បីនាក់ ក្នុងគ្រួសារ (អ្នកទាំងនោះមានអាយុក្រោម ១៤ឆ្នាំ) ធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋ ដែលនេះជាភាពទូទៅមួយនៅក្នុងសិប្បកម្មឡឥដ្ឋជាច្រើន ដែលមានកម្មករដាក់បញ្ចាំខ្លួនដើម្បីដោះបំណុល។

បន្ទាប់ពីកុមារីអាយុ ៩ឆ្នាំ នោះ បានដាច់ដៃ ម្ចាស់សិប្បកម្មឡឥដ្ឋបានប្រាប់ទៅក្រុមគ្រួសារថាបំណុល ដែលគ្រួសារនោះជំពាក់ត្រូវបានរួច។ ក្រុមគ្រួសារនោះ បច្ចុប្បន្នត្រឡប់ទៅផ្ទះរបស់អ្នកទាំងនោះវិញ ដោយសមាជិកមួយចំនួន ស៊ីឈ្នួលដឹកឈើដើម្បីបានប្រាក់។អ្នកទាំងនោះ បានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាថ្មីម្តងទៀត ដែលពេលនេះពួកគេខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចម្រើន។ គ្រួសារនេះមិនទាន់មានការយឺតយ៉ាវ ក្នុងការសងបំណុលនោះទេ ប៉ុន្តែជីដូនរបស់កុមារីនោះ បាននិយាយថា "វាពិបាកខ្លាំងណាស់រាល់ថ្ងៃ... ខ្ញុំអង្គុយក៏ពិបាកចិត្ត ដេកក៏ពិបាកចិត្តនឹងរឿងរកលុយ"។



[២៩] K. Brickell et al., "ឥដ្ឋដែលមានឈាម៖ រឿងរ៉ាវដែលត្រូវបានគេលាក់បាំងស្តីពីទាសភាពសម័យទំនើប និងការប្រែប្រួលអាកាសធាតុនៅកម្ពុជា", Royal Holloway, សាកលវិទ្យាល័យទីក្រុងឡុង ទំព័រទី១៩ ឆ្នាំ២០១៨

[៣០] Jan Ovesen & Ing-Britt Trankell, "ការមានទំនាក់ទំនងទៅវិញទៅមកនៃឥណទានខ្នាតតូច និងកម្ចីឯកជននៅកម្ពុជា" ទស្សនាវដ្តីផ្នែកនរវិទ្យានៅអាស៊ីប៉ាស៊ីហ្វិក ទំព័រទី ១៨៧ ដល់ ១៨៨ ឆ្នាំ២០១៤ "

[៣១] មាត្រា ១ (ក) អនុសញ្ញាបំពេញបន្ថែមស្តីពីការលុបបំបាត់អំពើទាសភាព ការជួញដូរទាសករ និងអង្គការអំពើប្រហាក់ប្រហែលនឹងអំពើទាសភាព ឆ្នាំ២០១៦

[៣២] មាត្រា ១ និង ២(ក) អនុសញ្ញាស្តីពីការធ្វើការងារដោយបង្ខំ (លេខ ២៩) ឆ្នាំ១៩៣០

## អ្នកចងការប្រាក់ឯកជន

គុណប្រយោជន៍មួយ នៃគុណប្រយោជន៍ដទៃទៀត នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺស្ថាប័នទាំងនោះ បានធ្វើឱ្យមានការកាត់បន្ថយតម្រូវការអ្នកចងការប្រាក់ឯកជន ដែលជាអ្នកចងការប្រាក់ ដោយអត្រាការប្រាក់ខ្ពស់ដោយក្នុង ករណីជាច្រើន គឺមានអត្រាការប្រាក់លើសពី ៣០ភាគរយ ក្នុងមួយខែ។ ការអះអាងខាងលើនេះ មិនត្រូវបានគាំទ្រដោយរបាយការណ៍នេះទេ ដោយក្នុងចំណោមពលរដ្ឋ ដែលត្រូវបានសម្ភាសចំនួន ២៨នាក់ មានពលរដ្ឋចំនួន ២២នាក់ បានខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជន ដើម្បីបំពេញបន្ថែមដើម្បីដោះបំណុល ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរបស់អ្នកទាំងនោះ។

ម ន្ត្រី ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តែងតែប្រាប់អតិថិជនរបស់ខ្លួនថា អតិថិជនទាំងនោះ មិនអាចខ្ចីប្រាក់ទៀតទេ ប្រសិនបើអ្នកទាំងនោះ មិនទាន់ដោះបំណុលចាស់ ។ គោលនយោបាយនេះមានបំណងដើម្បីការពារអតិថិជន ដោយមិនឱ្យខ្ចីប្រាក់ច្រើនដងពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ហើយគោលនយោបាយនេះ ត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារវិស័យ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានរាយការណ៍កាន់តែច្រើនឡើងៗអំពីទិន្នន័យនៃការខ្ចីប្រាក់ ទៅកាន់ការិយាល័យឥណទានកម្ពុជា។

ក៏ប៉ុន្តែ ការរកឃើញបង្ហាញថា គោលនយោបាយនេះ បានធ្វើឱ្យអតិថិជន ទៅខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជន ដើម្បីដោះបំណុល របស់អ្នកទាំងនោះនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ បន្ទាប់ពីដោះបំណុលរួចអ្នកទាំងនោះ តែងតែទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីទៅខ្ចីប្រាក់ក្នុងចំនួនច្រើនជាងមុន ដោយពេលខ្លះត្រឹមតែពីរបីថ្ងៃប៉ុណ្ណោះ ក្រោយពេលដោះបំណុលចាស់ ។ ការណ៍ដែលមានលទ្ធភាពដោះបំណុលចាស់ធ្វើឱ្យអ្ន កទាំងនោះងាយស្រួលក្នុងការខ្ចីប្រាក់ជាថ្មី។ បន្ទាប់មកអ្នកទាំងនោះ យកប្រាក់ដែលខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថ្មីនោះ ទៅដោះបំណុលពីអ្នកចងការប្រាក់ឯកជន ដែលករណីមួយចំនួន អ្នកចងការប្រាក់ឯកជននោះ គឺ ជាមេភូមិ។ បទពិសោធ ន៍ទូទៅនេះ គឺជាឧទាហរណ៍ច្បាស់មួយនៃវដ្តនៃបំណុលដែលកើត មាននៅក្នុងសហគមន៍ ដែលត្រូវបានស ម្ភាសដោយអ្នកស្រាវជ្រាវ។ នៅក្នុងករណីផ្សេងទៀត ពលរដ្ឋបានប្រើប្រាស់កម្ចីឯកជន ដើម្បីបំពេញការចំណាយ លើតម្រូវការមូលដ្ឋាន ដូចជាការទិញម្ហូបអាហារឬឱសថនៅខណៈដែលអ្នកទាំងនោះយកប្រាក់ចំណូលរបស់ខ្លួនទាំងអស់ ដើម្បីសងបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ការស្រាវជ្រាវនេះ បានរកឃើញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើនពឹងផ្អែកលើ អ្នកចងការប្រាក់ឯកជន ដើម្បីបង្កើតជាផ្នែកមួយ នៃវដ្តនៃបំណុល ដែលធ្វើឱ្យអ្នកខ្ចីប្រាក់ធ្លាក់ចូលក្នុងអន្ទាក់បំណុល ដោយដោះបំណុលមួយរួច ហើយទៅខ្ចីបំណុលថ្មី និងកាន់តែច្រើនឡើងៗ។ នៅក្នុងករណីមួយចំនួន មន្ត្រីឥណទានបានណែនាំ អ្នកចងការប្រាក់ឯកជនដល់អតិថិជន និងលើកទឹកចិត្ត ឱ្យអតិថិជនខ្លួនខ្ចីអ្នកចងការប្រាក់ឯកជននោះ ឬ មន្ត្រីទាំងនោះមិនដែលសួរអតិថិជនថា តើអ្នកទាំងនោះបានប្រាក់មកពីណា ច្រើនរាប់ពាន់ដុល្លារ ដើម្បីដោះបំណុលចាស់នោះទេ។ នៅក្នុងករណីមួយ មន្ត្រីឥណទានជាច្រើន របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់ (VisionFund) បានសន្យាថា នឹងផ្តល់កម្ចីថ្មីទៅអតិថិជនដែលកំពុងជាប់កម្ចីចាស់ ប្រសិនបើអតិថិជននោះ ព្រមទៅខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជនដើម្បីមកដោះបំណុលចាស់។ ករណីមួយទៀតមន្ត្រីឥណទាន របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ LOLC បានណែនាំអ្នកចងការប្រាក់ឯកជន ដល់អតិថិជនម្នាក់ដែលបានសងបំណុលយឺតយ៉ាវ ហើយបានលើកទឹកចិត្តអតិថិជននោះឱ្យខ្ចីប្រាក់ពីអ្នកចងការប្រាក់ឯកជននោះ ដើម្បីដោះបំណុលជាមួយ គ្រឹះស្ថានរបស់មន្ត្រីឥណទាននោះ។

ទោះបីជា មន្ត្រីឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើន មិនមានការ ជាប់ពាក់ព័ន្ធដោយផ្ទាល់ក៏ដោយ ក៏ការខ្ចី ប្រា ក់ក្រៅផ្លូវការ អាចបណ្តាលឱ្យមានផលវិបាកអវិជ្ជមានជាច្រើន។ អ្នកសម្ភាសន៍មួយរូបបានប្រាប់ថា មេភូមិម្នាក់ដើរតួជា អ្នកចងការប្រាក់ឯកជនដើម្បីផ្តល់កម្ចីក្រៅផ្លូវការ ដល់អតិថិជន របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហើយបន្ទាប់មក ក្លែងឯកសារដើម្បី លក់ដីរបស់អតិថិជននោះដោយមិនមាន ការព្រមព្រៀងពីអតិថិជននោះទេ។ ករណីមួយទៀតស្ត្រីចំណាស់ម្នាក់ ដែលស្ទើរតែគ្មានប្រាក់ចំណូល ហើយបានជាប់ក្នុងបំណុលរាប់ពាន់ដុល្លារ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានទៅជួបអ្នកចងការប្រាក់ឯកជនដើម្បីខ្ចីប្រាក់ដោះបំណុល ដែលក្រោ យមកអ្នកចងការប្រាក់នោះ បានបង្ខំ ឱ្យ អ្នកស្រីលក់ដី ស្រែ របស់អ្នកស្រីស្ទើរតែទាំងអស់ ដើម្បីដោះបំណុលរបស់អ្នកស្រី។

### ករណីសិក្សាអំពីកម្ចីក្រៅផ្លូវការ

ក្នុងអំឡុងពេលមួយឆ្នាំដំបូង សុភាបានបង់ប្រាក់ចំនួន ១.២៥០ ដុល្លារអាមេរិក នៃប្រាក់បំណុលសរុប ២.៧៥០ ដុល្លារអាមេរិក របស់នាងជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ HKL។ នាងបាន យ កប្រាក់កម្ចី ដើម្បីទៅដាំម្រេច និងស្រូវ ហើយ និង យកប្រាក់ខ្លះទៅសងបំណុលផ្សេងទៀត ដែលនាងមានជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់ និងធនាគារ អេស៊ីលីដា។ នាងធ្លាប់បានប្រាប់គ្រឹះស្ថានទាំងនោះថា នាងមិនអាចទាយដឹងច្បាស់ជាមុនថា ប្រាក់ចំណូលរបស់នាងមានចំនួនប៉ុន្មាននោះទេ ព្រោះនាងធ្វើការជាកម្មករស៊ីប្រាក់ ឈ្នួលប្រចាំថ្ងៃ ហើយទិន្នផលក្នុងចំការរបស់នាងពឹងផ្អែកលើតម្លៃក្នុងទីផ្សារកសិផល។ ទោះបីជាយ៉ាងនេះក្តី ក៏គ្រឹះស្ថាននីមួយៗនៅតែតម្រូវឱ្យដាក់តម្កល់ប្លង់ដី ដើម្បីទទួលបានប្រាក់កម្ចី។

អំឡុងពេលឆ្នាំទីពីរ នៃបំណុលជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ HKL សុភា បានធ្លាក់ខ្លួនឈឺ ហើយតម្លៃម្រេចចាប់ផ្តើមធ្លាក់ចុះ។ នៅពេលដែលនាងចាប់ផ្តើមសងបំណុលយឺតយ៉ាវ អ្នកជំនួញបានមកដល់ផ្ទះនាង ដោយមិនបានដឹងមុន ជាមួយនឹងអ្នកតំណាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ HKL។ អ្នកតំណាងនោះ បានរៀបចំឱ្យមានការលក់គ្រឿងយន្តភ្ជួរស្រែរបស់នាង ផ្ទុយពីឆន្ទៈរបស់នាង ដើម្បីដោះបំណុលរបស់នាង។ សុភា បាននិយាយថា "ខ្ញុំមិនចង់លក់វាទេ ប៉ុន្តែគេបានហៅនរណាម្នាក់មកទិញវា"។ ដោយមិនមានគ្រឿងយន្តភ្ជួរស្រែ នាងមិនអាចធ្វើស្រែលើដី ដើម្បីចិញ្ចឹមកូនរបស់នាងបានទេ ប៉ុន្តែនាងមិនមានលទ្ធភាពដើម្បីបញ្ឈប់ការលក់នោះ។

បន្ទាប់ពីការ លក់នោះ សុភាចាប់ផ្តើមសងបំណុលយឺតយ៉ាវជាមួយកម្ចីចំនួន ១.៥០០ ដុល្លារអាមេរិក របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់។ មន្ត្រីឥណទាន បានមកផ្ទះនាង ហើ យ ប្រាប់ឱ្យនាងលក់ផ្ទះរបស់នាង។ នាងបាននិយាយថា "ប្រសិនបើខ្ញុំលក់ផ្ទះ តើឱ្យខ្ញុំទៅនៅឯណា?"។ ជំនួសឱ្យការលក់ផ្ទះ នាងបានទៅខ្ចីលុយ ពីអ្នកចងការប្រា ក់ ឯ ក ជ ន ដើម្បីដោះបំណុលរបស់គ្រឹះស្ថានហិរញ្ញវត្ថុ វីសិនហ្វាន់។ នៅពេលនាងខកខានក្នុងការសងបំណុលអ្នកចងការប្រាក់ អ្នកចងការប្រាក់នោះបានទៅជួបមេភូមិ ហើយបង្ខំនាង ឱ្យផ្ទេរសិទ្ធិលើដីធ្លីរបស់នាងស្ទើរតែទាំងអស់ទៅឱ្យអ្នកទាំងនោះ។ ពួកគេបានយកដីធ្លីនៅជុំវិញផ្ទះរបស់នាង រួមទាំងដីក្រោយផ្ទះ។ ឥឡូវនាងរស់នៅក្នុងផ្ទះដែល ព័ទ្ធជុំវិញដោយដីដែលនាងត្រូវបានគេបង្ខំឱ្យលក់។ នាងនៅតែបារម្ភអំពីថាតើនាងនឹងដោះបំណុលដែលនៅសេសសល់របស់នាងដោយរបៀបណា នៅពេលដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអ្នកចងការប្រាក់ឯកជន បានយកដីរបស់នាងស្ទើរតែទាំងអស់ និងមាស៊ីនភ្ជួរស្រែរបស់នាងទៅហើយ។ នាងបាននិយាយថា "តើឱ្យខ្ញុំសប្បាយចិត្តយ៉ាងដូម្តេចទៅ បើខ្ញុំមិនមានប្រាក់ចំណូលផង? តើឱ្យខ្ញុំសងបំណុលគេយ៉ាងម៉េចទៅ?"

## បទបញ្ញត្តិ និងការការពារអ្នកប្រើប្រាស់ឥណទាន

បទបញ្ញត្តិការពារអ្នកប្រើប្រាស់ឥណទាន ដ៏មានប្រសិទ្ធិភាព គឺស្ទើរតែគ្មាន នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។ ធនាគារជាតិនៃកម្ពុជា គឺជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រង និង ផ្តល់អាជ្ញាប័ណ្ណដល់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ប៉ុន្តែធនាគារជាតិបានដាក់ចេញបញ្ញត្តិ ការពារអ្នកប្រើប្រាស់ ឥណទានតិចតួចប៉ុណ្ណោះ ហើយក្នុងចំណោមបញ្ញត្តិទាំងនោះ គឺគ្មានបញ្ញត្តិណាមួយមានឥទ្ធិពលជាវិជ្ជមាន ដល់ជីវភាពរបស់អតិថិជន របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនោះទេ។ តុលាការ ត្រូវបានផ្តល់អំណាចឱ្យការពារ និងពិនិត្យលើការខកខានសងបំណុលរបស់អ្នកខ្ចី ប៉ុន្តែអំពើពុករលួយជាប្រព័ន្ធ និង មិនសូវឆ្លងតាមនីតិវិធីតុលាការ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បណ្តាលឱ្យអ្នកខ្ចីម្នាក់ៗមិនចង់ ឬ មិនមានលទ្ធភាពទាមទារសិទ្ធិស្របច្បាប់របស់ខ្លួន ពាក់ព័ន្ធនឹងបំណុល។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចេតនាបង្ហាញថា ខ្លួននិងមន្ត្រីរបស់ខ្លួនអនុវត្តតាមច្បាប់ ដើម្បីប្រកាន់ខ្ជាប់តាម គោលការណ៍ក្រមសីលធម៌ ប៉ុន្តែមិនមានយន្តការអនុវត្តច្បាប់ក្រៅប្រព័ន្ធតុលាការ ដើម្បីអនុវត្តវិធានការច្បាប់នោះទេ ឬមិនមាន ភស្តុតាងដែលបង្ហាញថាអ្នកទាំងនោះជោគជ័យ ក្នុងការការពារអតិថិជនទាំងនោះនោះទេ។

ច្បាប់ស្តីពីធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុឆ្នាំ១៩៩៩បានឱ្យនិយមន័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថា ជាអ្នកផ្តល់នូវប្រាក់កម្ចី និង ទទួលប្រាក់បញ្ញើ ដល់ពលរដ្ឋក្រីក្រ អ្នកដែលមានប្រាក់ចំណូលទាប និង អាជីវកម្មខ្នាតតូច ដូចដែលមានបញ្ញត្តិដោយធនាគារជាតិនៃកម្ពុជា។[៣៣] មានតែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានភាគហ៊ុនច្រើនជាង ២៥០ លានរៀល (៦១.៥០០ ដុល្លារអាមេរិក) ប៉ុណ្ណោះទើបអាចទទួលបានអាជ្ញាប័ណ្ណ។ តិចជាងនេះ គឺហៅថា "អង្គការមិនមែនរដ្ឋាភិបាល" ដែលតម្រូវឱ្យត្រឹមតែចុះបញ្ជីប៉ុណ្ណោះ។ អាជ្ញាប័ណ្ណដែលមិនមានកំណត់ពេលក្នុងការប្រតិបត្តិការ គឺត្រូវបានផ្តល់ឱ្យដល់អ្នកស្នើសុំដែលបានស្នើសុំជោគជ័យ។[៣៤] គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណ ប្រឈមមុខនឹង បញ្ញត្តិតឹងរ៉ឹងជាងមុន ដើម្បីធានានូវទ្រព្យសកម្ម និង ការពារអ្នកវិនិយោគទុន ដូចជាវិធានការច្បាប់មួយចំនួន ដែលតម្រូវឱ្យ គ្រឹះស្ថានទាំងនោះមានប្រាក់តម្កល់ក្នុងធនាគារជាតិ[៣៥] ប៉ុន្តែចំពោះវិធានការការពារអ្នកប្រើប្រាស់ឥណទាន គឺមានតិចតួចណាស់ដែលត្រូវបានបញ្ញត្តិជាច្បាប់។ ដោយសារគ្រឹះស្ថានទាំងនោះ អាចបង្ហាញថាមានសមត្ថភាពក្នុងការគ្រប់គ្រង និងរកប្រាក់ចំណូល ដូចនេះបន្ទាប់មកគ្រឹះស្ថានទាំងនោះអាចស្នើសុំអាជ្ញាប័ណ្ណដាច់ដោយឡែកមួយទៀត ដើម្បីប្រមូលប្រាក់បញ្ញើពីសាធារណជន[៣៦] ដែលមិនត្រូវបានធានាដោយស្ថាប័នរដ្ឋណាមួយ។ អ្នកខ្ចីប្រាក់ភាគច្រើន ខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយការផ្តិតមេដៃលើកិច្ចសន្យាផ្លូវការ និងថតចម្លងចេញរួចទៅហើយ ហើយត្រូវបានទទួលស្គាល់ពីអាជ្ញាធរក្នុងតំបន់ ភាគច្រើនគឺមេឃុំ។

ច្បាប់កម្ពុជា អនុញ្ញាតឱ្យអ្នកខ្ចីដាក់បញ្ចាំអចលទ្រព្យ ដោយប្រគល់ទ្រព្យនោះឱ្យម្ចាស់បំណុលកាន់កាប់ ដើម្បីធានាការសងបំណុល។ ច្បាប់ ក៏តម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុប្តឹងទៅតុលាការ ដើម្បីសុំលក់ទ្រព្យបញ្ចាំ នៅពេលកូនបំណុលមិនមានលទ្ធភាពសងបំណុល។[៣៧] ធនាគារពិភពលោក បានកត់សំគាល់ថា នីតិវិធីតុលាការហាក់ដូចជាធានានូវប្រយោជន៍កូនបំណុល ដែលល្អជាងការដោះស្រាយបញ្ហាបំណុលក្រៅប្រព័ន្ធតុលាការ ដែលផ្តល់ប្រយោជន៍ដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុច្រើនជាងកូនបំណុល។[៣៨] ប៉ុន្តែ លក្ខខណ្ឌតម្រូវទាំងនេះតែងតែមិនត្រូវបានអនុវត្តដោយគ្រឹះស្ថានទាំងនោះ ដែលដូចដែលបានលើកឡើងខាងលើ តែងតែដាក់សម្ពាធលើអតិថិជនឱ្យលក់ដីធ្លី ដោយមិនបាច់ឆ្លងតាមនីតិវិធីតុលាការ។ កង្វះខាតការយល់ដឹងផ្លូវច្បាប់របស់អតិថិជនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អត្រាអក្ខរភាពផ្នែកហិរញ្ញវត្ថុទាប និងការមិនសូវមានទំនុកចិត្តរបស់សាធារណជនលើប្រព័ន្ធយុត្តាធិការកម្ពុជាដែលភាគច្រើនមានអំពើពុករលួយ ធ្វើឱ្យអតិថិជន តិចតួចទាមទារសិទ្ធិរបស់ខ្លួនតាមរយៈនីតិវិធីតុលាការ។

ក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់ថាកិច្ចសន្យា ត្រូវតែស្របនឹងសណ្តាប់ធ្នាប់សាធារណៈ និង "ទំនៀមទំលាប់ល្អ"[៣៩] ដែលមានន័យថាពលរដ្ឋត្រូវគោរពតាមវិធានការ ទំនៀមទំលាប់ និង ច្បាប់ ដែលមានចែងជាលាយលក្ខណ៍អក្សរ។ លើសពីនេះ ក្រមរដ្ឋប្បវេណីបាន

[៣៣] "និយតករ/យន្តការផ្លូវច្បាប់" សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា អាចទាញយកបានតាមរយៈ៖ https://www.cma-network.org/en/regulators-legal-framework. សូមមើលផងដែរមាត្រា ២ នៃប្រកាសស្តីពីការចុះបញ្ជី និងការផ្តល់អាជ្ញាប័ណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០០២

[៣៤] មាត្រា ៩ នៃប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០០០

[៣៥] មាត្រា ១៦ នៃប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុ ឆ្នាំ២០០០

[៣៦] ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ឆ្នាំ២០០៧

[៣៧] មាត្រា ២០៦ នៃច្បាប់ភូមិបាល ឆ្នាំ២០០១

[៣៨] "ការអនុវត្តជាវិជ្ជមានសម្រាប់ការការពារអតិថិជនហិរញ្ញវត្ថុ" ធនាគារពិភពលោក ទំព័រ២៤ ឆ្នាំ២០១២ អាចទាញយកបានតាមរយៈ៖ http://responsiblefinance.worldbank.org/~/media/GIAWB/FL/Documents/Misc/Good-practices-for-financial-consumer-protection.pdf.

[៣៩] មាត្រា ៣៥៤ និង ៣៥៧ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧

ចែងនូវមធ្យោបាយជាច្រើន ដែលធ្វើឱ្យកិច្ចសន្យា ត្រូវបានចាត់ទុកជាមោឃៈដូចជា "ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើង ដោយអំពើឆ្លៀតឱកាស ដោយមានគោលបំណង កេងយកចំណេញហួសហេតុ"[៤០]។ មាត្រាមួយទៀត បានចែងថាប្រសិនបើ "ភាគីនៃកិច្ចសន្យាម្ខាងប្រើប្រាស់ឋានៈខ្លួន ដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀត ដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះ អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ"[៤១] ។ការឱ្យខ្ចីប្រាក់ដែលមានលក្ខណៈទាញប្រយោជន៍ពី អ្នកក្រ និងស្ថានភាពសេដ្ឋកិច្ចមិនស្មើគ្នាទាំងនេះ គឺជាឫសគល់ចម្បងមួយនៃឫសបញ្ហាជាច្រើន ដែលត្រូវបានចងក្រងទុកក្នុងអំឡុងពេលនៃការស្រាវជ្រាវ។

លើសពីនេះ នាយកប្រតិបត្តិនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានប្រាប់អ្នកស្រាវជ្រាវថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុខ្នាតតូចមួយចំនួន ពេលខ្លះណែនាំអតិថិជនរបស់ខ្លួនទៅកាន់ការខ្ចីប្រាក់ក្រៅផ្លូវការ ដែលមិនមានការគ្រប់គ្រងត្រឹមត្រូវ ដូចជាអ្នកចងការប្រាក់ឯកជន ឬហាង បញ្ចាំ ដើម្បីទាញយកប្រយោជន៍បន្ថែមទៀត ពីពលរដ្ឋ ដែលកំពុងជាប់បំណុលស្រាប់។ ឯកសារចុះបញ្ជីអាជីវកម្មកម្ពុជា បានបញ្ជាក់ថាមានទំនាក់ទំនងរវាងម្ចាស់ភាគហ៊ុន នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុខ្នាតតូចមួយចំនួន និងម្ចាស់ហាងបញ្ចាំ ក៏ដូចជាក្រុមហ៊ុនអចលនទ្រព្យមួយចំនួន។

ពលរដ្ឋដែលត្រូវបានសម្ភាសជាច្រើន មិនដែលទទួលបានលក្ខខណ្ឌនៃកិច្ចសន្យា ជាក្រដាសមានលាយលក្ខណ៍អក្សរនោះទេ ទោះបីជាអ្នកទាំងអស់នោះ អាចអាន ឬអាចឱ្យគេពន្យល់ ពីអត្ថន័យនៃលក្ខខណ្ឌទាំងនោះក៏ដោយ។ ភាគច្រើននៃពលរដ្ឋទាំងនោះ មិនមានលទ្ធភាពរកសេវាផ្នែកច្បាប់ ឬការប្រឹក្សាផ្នែកច្បាប់ នៅពេលដែលពួកគេជួបបញ្ហា ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនោះទេ។ ការមិនទុកចិត្តតុលាការ កង្វះខាតចំណេះដឹងផ្នែកច្បាប់ និងកង្វះខាតការគាំទ្រផ្នែកច្បាប់ បណ្តាលឱ្យបញ្ហាយ៉ាងច្រើនពាក់ព័ន្ធនឹងការសងបំណុលទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវធ្វើការដោះស្រាយនៅក្រៅប្រព័ន្ធតុលាការ ដោយមានការជួយសម្របសម្រួលដោយអាជ្ញាធរក្នុងតំបន់។ នេះ គឺជាការព្រួយបារម្ភមួយ នៅពេលដែលមានទំនាស់ផលប្រយោជន៍កើតឡើង ដោយអាជ្ញាធរក្នុងតំបន់មួយចំនួនទទួលបានប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីជួយឱ្យមានការសងបំណុលនៅក្នុងសហគមន៍របស់អ្នកទាំងនោះ។

សមាគមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) បានបង្ហាញអំពីក្រមសីលធម៌ថ្មីមួយសម្រាប់សមាជិកទាំង ៨៧ គ្រឹះស្ថានរបស់ខ្លួននៅ ឆ្នាំ ២០១៧ ដែលមានគោលដៅ "ពង្រឹងសុចរិតភាព" របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយធ្វើការថ្កោលទោសការអនុវត្តជាក់លាក់មួយចំនួនដែលគ្មានសីលធម៌។[៤២] គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១៨ នៅកម្ពុជា បានគាំទ្រយុទ្ធនាការវៃឆ្លាត (Smart Campaign) ការប្តេជ្ញាចិត្ត ជាអន្តរជាតិ ដើម្បីសម្រេចបាននូវឧស្សាហកម្មមីក្រូហិរញ្ញវត្ថុមួយដែលផ្តោតលើវិស័យហិរញ្ញវត្ថុ និងសង្គម។[៤៣] ការប្រតិបត្តិតាមក្រមសីលធម៌អន្តរជាតិទាំងនេះ ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគឺជាការស្ម័គ្រចិត្ត។ ក្រមសីលធម៌នេះ មិនមានយន្តការខាងក្រៅក្នុងការចាប់បង្ខំឱ្យប្រតិបត្តិតាមនោះទេ៖ ការគ្រប់គ្រងរបស់ធនាគារជាតិទៅលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺបច្ចុប្បន្ននៅមានកម្រិត ក្នុងការត្រួតពិនិត្យទៅលើការប្រតិបត្តិតាមច្បាប់ និងគោលការណ៍ហិរញ្ញវត្ថុ។ ក្រមសីលធម៌នេះ មិនបានពង្រីកដល់ការធានាយ៉ាងមានប្រសិទ្ធិភាពថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនោះ ប្រតិបត្តិការប្រកបដោយសីលធម៌ និងការទទួលខុសត្រូវនោះទេ។ ការសិក្សាមួយអំពីឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ នៅក្នុងប្រទេសសាធារណរដ្ឋដូមីកង់ បានរកឃើញថាការពង្រឹងការអនុវត្តច្បាប់ដោយខ្លួនឯង មិនទាន់គ្រប់គ្រាន់ក្នុងការការពារអ្នកប្រើប្រាស់ឥណទានពីការជាប់ផុងក្នុងវិបត្តិបំណុលនោះទេ។ ការសិក្សាបានរកឃើញថា នៅពេលដែលពឹងលើការពង្រឹងការអនុវត្តច្បាប់ដោយខ្លួនឯងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើម្បីការពារអតិថិជនផលប្រយោជន៍ និងសុខុមាលភាពរបស់អតិថិជន មិនត្រូវបានគ្រឹះស្ថានយកចិត្តទុកដាក់ ដូចប្រាក់ចំណូលរបស់គ្រឹះស្ថាននោះទេ។[៤៤]

នៅឆ្នាំ ២០១៧ រាជរដ្ឋាភិបាល បានធ្វើយុទ្ធនាការមួយ ដើម្បីធានាថា អតិថិជនរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដឹងថា ស្ថាប័នទាំងនោះ មិនមែនជាស្ថាប័នរបស់រដ្ឋនោះទេ។ សេចក្តីណែនាំមួយ ដែលបានបញ្ជាក់អំពីភាពខុសគ្នានៃស្ថាប័នទាំងពីរនេះ ក៏បានបញ្ចូលក្រមសីលធម៌របស់សមាគម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានលើកឡើងខាងលើផងដែរ។[៤៥] ធនាគារធំៗ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើន រួមមានធនាគារ អេស៊ីលីដា ត្រូវបង្ខំចិត្តផ្លាស់ប្តូររូប

[៤០] មាត្រា ៣៤៥(៣) នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧

[៤១] មាត្រា ៣៤៩(១) នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[៤២] ហ៊ា គីមសាយ "សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាបង្កើតក្រមសីលធម៌សម្រាប់មីក្រូហិរញ្ញវត្ថុក្នុងស្រុក" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ អាចទាញយកបានតាមរយៈ៖ https://www.phnompenhpost.com/business/cma-issues-code-conduct-local-mfis.

[៤៣] "ប្រទេសកម្ពុជា" យុទ្ធនាការវៃឆ្លាត ២០១៩ អាចទាញយកបានតាមរយៈ៖ https://www.smartcampaign.org/tools-a-resources/730.

[៤៤] J. Afonso et al., "Doing Good by Doing Well? Microfinance, Self-Regulation and Borrowers' Over-Indebtedness in the Dominican Republic", ទន្និនុប្បវត្តិផ្នែកអភិវឌ្ឍន៍ជាអន្តរជាតិ ទំព័រ ៩៣១ ដល់ ៩៣២ ឆ្នាំ២០១៦

[៤៥] សូមមើលកំណត់សម្គាល់ខាងលើលេខ ៣៨

សញ្ញារបស់ខ្លួន ដែលមានរូបដូចនឹងរូបសញ្ញារបស់ស្ថាប័នរដ្ឋ ហើយ សម្តេចនាយករដ្ឋមន្ត្រី បានបង្គាប់ឱ្យក្រុមហ៊ុនសេវាទូរស័ព្ទទាំងអស់ ផ្ញើសារជាសំឡេង និង អក្សរទៅកាន់អតិថិជន របស់ខ្លួន ដើម្បីជូនដំណឹងថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ គឺជាស្ថាប័នឯកជន។[៤៦] គោលនយោបាយទាំងនេះភាគច្រើន កើតមានឡើង ដោយសារ ការព្រួយបារម្ភអំពីការយល់ដឹងរបស់សាធារណជន នៅពេលដែលមាន ការប្រព្រឹត្តខុសច្បាប់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន។ គោលនយោបាយទាំងនោះ អាចមានឥទ្ធិពលដល់ការការពាររាជរដ្ឋាភិបាល ប៉ុន្តែមិនបានជួយការពារដល់អតិថិជននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនោះទេ។

នៅខែមីនា ឆ្នាំ២០១៧ នៅមុនពេលមានការបោះឆ្នោតថ្នាក់ឃុំ-សង្កាត់ រាជរដ្ឋាភិបាល បានដាក់ចេញនូវពិដាន អត្រាការប្រាក់ប្រចាំឆ្នាំថ្មីមួយ ត្រឹម ១៨ ភាគរយក្នុងមួយឆ្នាំ សម្រាប់កម្ចីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុថ្មី។[៤៧] វិធានការនេះគឺដើម្បី "ការពារអតិថិជនពីការដាក់អត្រាការប្រាក់ ខ្ពស់ហួសហេតុពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ដើម្បីលើកកម្ពស់ ការប្រើប្រាស់កម្ចី ដែលសមរម្យឱ្យមានប្រសិទ្ធិភាព"[៤៨]។ មុនពេលមានការកំណត់ ពិដានអត្រាការប្រាក់ថ្មីនេះ អត្រាការប្រាក់ជាទូទៅ មានចន្លោះពី ២០ ទៅ ៣០ ភាគរយក្នុងមួយឆ្នាំ។[៤៩] មិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលនោះទេ ពិដានអត្រាការប្រាក់ថ្មីនេះ មិនត្រូវបានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលយកនោះទេ៖ គ្រឹះស្ថានទាំងនោះ បានលើកឡើងពីបញ្ហា អំពីលទ្ធភាពរបស់ពួកគេក្នុងការរក្សានូវកម្រិតខ្ពស់ នៃការផ្តល់ប្រាក់កម្ចីថ្ងៃមុខទៀត។ ការរុញច្រានរបស់គ្រឹះស្ថានទាំងនេះ គឺផ្តោតទៅលើបញ្ហាពីរគឺ៖ ទីមួយ ការផ្គត់ផ្គង់ឥណទានខ្នាតតូច នឹងត្រូវលែងមាន ប្រសិនបើគ្រឹះស្ថានទាំងនោះ មិនអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ និងទីពីរ នៅពេលលែងមានការផ្តល់ឥណទានខ្នាតតូច ពលរដ្ឋក្រីក្រកម្ពុជានឹងរឹតតែពឹងផ្អែកទាំងស្រុង លើការខ្ចីប្រាក់ពីភ្នាក់ងារចងការប្រាក់ឯកជន ដែលមានអត្រាការប្រាក់ខ្ពស់សម្រាប់កម្ចីខ្នាតតូច។[៥០] បន្ទាប់មក រាជរដ្ឋាភិបាល បានធ្វើការ "ការពារនិរន្តភាព" នៃវិស័យមីក្រូហិរញ្ញវត្ថុកាលពីខែវិច្ឆិកា ឆ្នាំ២០១៧ ដោយកាត់បន្ថយពន្ធដែលតម្រូវឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបង់ទៅលើកម្ចីបរទេសពី ១៤ មកត្រឹម ១០ ភាគរយ។[៥១] ការរីកលូតលាស់ និងប្រាក់ចំណូលនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ បន្តកើនឡើង បន្ទាប់ពីត្រូវបានដាក់ពិដានអត្រាការប្រាក់ នៅពេលដែលគ្រឹះស្ថានទាំងនោះ ចាប់ផ្តើមប្រើប្រាស់មធ្យោបាយផ្សេងទៀត ដើម្បីបង្កើតចំណូលរបស់ខ្លួន ដូចជាកម្រៃបង់មុនទទួលបានប្រាក់កម្ចី (up-front fees)។

ការណ៍ត្រូវបានបញ្ជាក់ តាមរយៈការស្រាវជ្រាវនេះ និងការទទួលស្គាល់ពីធនាគារជាតិ នៅក្នុងរបាយការណ៍របស់ខ្លួន ឆ្នាំ២០១៩ ដែលបង្ហាញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានបង្កើនប្រាក់ចំណូលរបស់ខ្លួនតាមរយៈកម្រៃនេះគុណនឹងពីរធៀបនឹងឆ្នាំ ២០១៨។[៥២] ប្រាក់កម្រៃនេះ ដែលត្រូវបានឃ្លាំមើល ដោយអ្នកស្រាវជ្រាវជាច្រើន ត្រូវបានគេយក ដោយគិតជាភាគរយកាត់ពីប្រាក់កម្ចី នៅពេលដែលអ្នកខ្ចីទទួលបានប្រាកកម្ចី។ អត្រាការប្រាក់របស់ប្រាក់កម្ចី គឺជាអត្រាការ ប្រាក់របស់ប្រាក់កម្ចីទាំងមូល ដោយមិនបានដកចេញនូវប្រាក់កម្រៃបង់មុននោះទេ។ វិធានការណ៍នេះ បានធ្វើឱ្យអត្រាការប្រាក់អាចមានកម្រិតលើសពីពិដានការប្រាក់ ១៨ភាគរយ ក្នុងមួយឆ្នាំ ដែលបានកំណត់ដោយរាជរដ្ឋាភិបាល។ នេះបានបង្ហាញថាការព្យាយាមរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងវិស័យហិរញ្ញវត្ថុ មិនទាន់មានប្រសិទ្ធិភាពនៅឡើយ ជាពិសេសក្នុងការការពារអតិថិជនរបស់គ្រឹះស្ថាន។

---

[៤៦] គួច ណារ៉ែន "ក្រុមហ៊ុនទូរស័ព្ទចល័ត ត្រូវបានប្រាប់ឱ្យផ្សព្វផ្សាយសារថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនមែនជារបស់រដ្ឋទេ" កាសែតឌឹខេមបូឌាដេលី ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ អាចទាញយកបានតាមរយៈ៖ https://www.cambodiadaily.com/news/mobile-firms-told-to-spread-message-mfis-not-state-run-125665/.

[៤៧] មាត្រា ៤ នៃប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន ឆ្នាំ២០១៧

[៤៨] មាត្រា ២ នៃប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន ឆ្នាំ២០១៧

[៤៩] ហ៊ា គីមសាយ "រាជរដ្ឋាភិបាលកាត់បន្ថយបន្ទុកពន្ធសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់ពីក្រៅប្រទេស" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ អាចទាញយកបានតាមរយៈ៖ https://www.phnompenhpost.com/business/government-reduces-tax-load-mfis-receiving-money-abroad.

[៥០] Daniel Rozas, "ពិដានអត្រាការប្រាក់ នឹងប៉ះពាល់គ្រួសារជនបទ" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧អាចទាញយកបានតាមរយៈ៖ www.phnompenhpost.com/analysis-and-op-ed/interest-rate-cap-will-hurt-rural-families.

[៥១] ដូចខាងលើ

[៥២] "ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុប្រចាំឆ្នាំ ២០១៩" ធនាគារជាតិនៃកម្ពុជា ទំព័រ ២៣ ខែមេសា ឆ្នាំ២០១៩ អាចទាញយកបានតាមរយៈ៖ https://www.nbc.org.kh/download_files/publication/annual_rep_eng/FSR-for-publication-final-22Apr2019.pdf.

# អនុសាសន៍

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងដៃគូកម្ចី៖

1. សហការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិ ដើម្បីបង្កើតនូវកម្មវិធីដោះបន្ទុកនៃបំណុល ដែលធានាថាអតិថិជន នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មិនតម្រូវឱ្យលក់ដីធ្លី ដើម្បីដោះបំណុលរបស់អ្នកទាំងនោះទេ។ គោលដៅចម្បងនៃកម្មវិធីគឺជាការលុបបំបាត់ការលក់ដីធ្លីរបស់អតិថិជនដោយបង្ខំ។
2. ធ្វើការស៊ើបអង្កេត និងស្រាវជ្រាវបន្ថែមពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្ស ដែលបណ្តាលមកពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយបង្កើតនូវយន្តការត្រួតពិនិត្យមួយដែលរឹងមាំ និងទៀងទាត់ ដើម្បីវាយតម្លៃស្ថានភាពរបស់អ្នកខ្ចីប្រាក់នៅក្នុងប្រទេសកម្ពុជា។
3. ទាមទារឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បញ្ឈប់នូវការបង្ខំអតិថិជនខ្លួន ឱ្យលក់ដីធ្លីនៅក្រៅប្រព័ន្ធតុលាការ បញ្ឈប់ការផ្តល់កម្ចីលក្ខណៈអសីលធម៌ និងចាត់វិធានការសមរម្យ ដើម្បីកាត់បន្ថយចំនួននៃការលក់ដីធ្លី ដើម្បីដោះបំណុល។
4. បង្កើត និងផ្តល់ជំនួយដល់កម្មវិធីគាំទ្រដល់ជនក្រីក្រនៅកម្ពុជា ដែលអាចផ្តល់នូវប្រាក់កម្ចីដោយមិនចាំបាច់តំកល់ប្លង់ដី ឬរំលោភទៅលើសិទ្ធិមនុស្សនានារបស់អតិថិជន។

រាជរដ្ឋាភិបាលកម្ពុជា៖

1. ធានាថាអាជ្ញាធរក្នុងតំបន់ នឹងមិនទទួលយកកម្រៃពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីដាក់សម្ពាធដល់ អតិថិជនក្នុងការដោះបំណុលនោះទេ។
2. បង្កើតច្បាប់ ដែលហាមឃាត់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីការដាក់សម្ពាធលើអតិថិជន ឱ្យលក់ដីធ្លី ដើម្បីធានាថាមាននីតិវិធីច្បាប់សម្រាប់អតិថិជនដែលមិនមានលទ្ធភាពសងបំណុល។
3. ធានាថា ភាគីពាក់ព័ន្ធ និងអ្នកវិនិយោគទុននៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រួមទាំងម្ចាស់ជំនួយទ្វេភាគី ធ្វើ ការឃ្លាំមើលនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងលើកទឹកចិត្តអ្នកទាំងនោះ ឱ្យបង្កើត និងផ្តល់ជំនួយដល់កម្មវិធីគាំទ្រជនក្រីក្រ។
4. សហការជាមួយដៃគូគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងដៃគូកម្ចី ដើម្បីបង្កើតកម្មវិធីដោះបន្ទុកបំណុល ដើម្បីកម្រិតចំនួននៃការលក់ដីដើម្បីដោះបំណុល។
5. រៀបចំកម្មវិធីជាមួយសហគមន៍អភិវឌ្ឍន៍អន្តរជាតិ ដើម្បីបង្កើតច្បាប់ ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ និង លក្ខណៈនៃសាវតា និងស្ថាប័នដទៃទៀត ដែលតម្រូវឱ្យស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក ដែលគ្រប់គ្រងដោយបុគ្គលឯកជន ឬ ដោយសហគមន៍ រួមបញ្ចូលគ្នា ដែលក្នុងរយៈពេលវែងនឹងជំនួសគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៖

1. ផ្លាស់ប្តូរបទបញ្ជាផ្ទៃក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីហាមឃាត់ការទាមទារឱ្យមានការដាក់តម្កល់ប្លង់ដី ទុកជាទ្រព្យបញ្ចាំសម្រាប់កម្ចីមីក្រូហិរញ្ញវត្ថុថ្មីទាំងអស់។
2. គណនា និងចេញផ្សាយជាសាធារណៈនូវចំនួនប្លង់ដីដែលត្រូវបានតំកល់ជាទ្រព្យបញ្ចាំ។
3. បញ្ឈប់ការដាក់សម្ពាធលើអតិថិជន ឱ្យលក់ដីធ្លី ដើម្បីដោះបំណុល ហើយជំនួសដោយការប្រើប្រាស់យន្តការផ្លូវច្បាប់ដែលមានស្រាប់សម្រាប់អតិថិជនដែលគ្មានលទ្ធភាពដោះបំណុល។
4. បញ្ឈប់ការប្រើប្រាស់ការយកកម្រៃបង់មុន ដែលបណ្តាលឱ្យអត្រាការប្រាក់ពិតលើសពីពិដានអត្រាការប្រាក់ ១៨ភាគរយក្នុងមួយឆ្នាំ ដែលត្រូវបានកំណត់ដោយធនាគារជាតិកម្ពុជា កាលពីខែមីនា ឆ្នាំ២០១៧។
5. គាំទ្រ និងសម្របសម្រួលការឃ្លាំមើលឯករាជ្យ ទៅលើការអនុវត្តនានារបស់គ្រឹះស្ថាន និងធានាឱ្យមានការជួយសម្រាលបន្ទុក និងសំណងដល់អតិថិជន នៅពេលដែលរកឃើញថាមានកំហុសក្នុងការ អនុវត្តរបស់គ្រឹះស្ថាន។

# ភាពជាម្ចាស់កម្មសិទ្ធិ

## ភាពជាម្ចាស់កម្មសិទ្ធិ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំបំផុតនៅកម្ពុជា ត្រូវបានបង្កើតឡើងដោយមានការគាំទ្រ និង ជួយផ្នែកហិរញ្ញវត្ថុ ពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ហើយគ្រឹះស្ថានមួយនៅតែត្រូវបានបន្តគ្រប់គ្រង ឬទទួលជំនួយផ្នែកហិរញ្ញវត្ថុ ពីទីភ្នាក់ងារទាំងនោះ។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ជាម្ចាស់ភាគហ៊ុនភាគតិច នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រិត ហើយចាប់តាំងពីឆ្នាំ ២០១៥ បានផ្តល់ប្រាក់កម្ចីជាង ៣០០ លានដុល្លារអាមេរិក ដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដើម្បី ពង្រីកភាគហ៊ុនកម្ចីរបស់អ្នកទាំងនោះ ដែលក្នុងនោះ ១១២ លានដុល្លារអាមេរិក គឺជាប្រាក់កម្ចី ដោយផ្ទាល់ពីគណនីរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ។ ទីភ្នាក់ងារអន្តរជាតិជាច្រើន និងធនាគាររដ្ឋនៃបណ្តាប្រទេសមួយចំនួនដូចជា សហគមន៍អឺរ៉ុប អាឡឺម៉ង់ បារាំង ចក្រភពអង់គ្លេស ហូឡង់ ជប៉ុន និងប្រទេសដទៃទៀត គឺស្ថិតក្នុងចំណោមម្ចាស់ភាគហ៊ុន ឬដៃគូកម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំៗនៅកម្ពុជា។ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍអន្តរជាតិ (USAID) ផ្តល់នូវការគាំទ្រចំបងៗ នៅក្នុងការអភិវឌ្ឍវិស័យនេះនៅពេលដំបូង ហើយបន្តផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុ ដល់វិស័យនេះរហូតដល់ឆ្នាំ ២០១៨។ ដៃគូកម្ចីឯកជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានដូចជាធនាគារ im Bustum Es-sen ដែលមានដាក់ពាក្យស្លោកថា "ការធ្វើប្រតិបត្តិការធនាគារប្រកបដោយយុត្តិធម៌" ហើយរាប់បញ្ចូលព្រះវិហារសាសនាគ្រិសកាតូលិកថាជាស្ថាបនិកមួយ និងធនាគារ Triodos Bank ដែលហៅខ្លួនឯងថាជា "អ្នកត្រួសត្រាយផ្លូវអន្តរជាតិសម្រាប់ការធ្វើប្រតិបត្តិការធនាគារប្រកបដោយនិរន្តភាព"។

មធ្យោបាយអសីលធម៌ ដែលត្រូវបានប្រើប្រាស់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានធ្វើឱ្យពលរដ្ឋកម្ពុជាជាច្រើន បាត់បង់ដីស្រែ និងផ្ទះសម្បែង កាត់បន្ថយសុវត្ថិភាពអាហារ រួមចំនែកបង្កើតឱ្យមានការប្រើប្រាស់ពលកម្មកុមារ និងពលករចំណាកស្រុក ហើយបណ្តាលឱ្យកើតមានការរំលោភសិទ្ធិមនុស្សជាច្រើននៅក្នុងប្រទេសកម្ពុជា។ បញ្ហានីមួយៗទាំងនេះ បានបង្កើតឱ្យមានការព្រួយបារម្ភមួយយ៉ាងខ្លាំង។ បញ្ហាទាំងនេះ អាចនឹងរីករាលដាល នៅពេលដែលកម្រិតនៃបំណុលនៅកម្ពុជាបន្តកើនឡើង។ មកដល់បច្ចុប្បន្ននេះ មិនទាន់មានការស្រាវជ្រាវ ជាសាធារណៈណាមួយ ត្រូវបានធ្វើឡើងដោយដៃគូគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬ ម្ចាស់ជំនួយ ដើម្បីស្វែងរកផលប៉ះពាល់អវិជ្ជមាន នៃការមិនមានលទ្ធភាពដោះបំណុលនៅកម្ពុជានៅឡើយទេ។

ខាងក្រោមនេះ គឺ ជាតារាងម្ចាស់ភាគហ៊ុន នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំៗនៅក ម្ពុជាទាំងប្រាំពីរគ្រឹះស្ថាន ដូចជាធនាគារ អេស៊ីលីដា និងស្ថាបនា។ ប្រភពនៃព័ត៌មាននេះ រួមមានបញ្ជីធុរកិច្ចកម្ពុជា របាយការណ៍ ប្រ ចាំ ឆ្នាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ គេហទំព័រ និងរបាយការណ៍របស់ម្ចាស់ភាគហ៊ុន និងទិន្នន័យឧស្សាហកម្ម។

**ភាគបែងនៃឥណទានតាមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
(គិតជាដុល្លារអាមេរិក)



# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់**

**LANKA ORIX LEASING COMPANY PLC (LOLC)**
ភាគហ៊ុន៖ ៧០%
ប្រភព៖ ប្រទេស ស្រីលង្កា

**THE BANK OF EAST ASIA (BEA)**
ភាគហ៊ុន៖ ២១%
ប្រភព៖ ហុង កុង

**PRASAC STAFF COMPANY**
ភាគហ៊ុន៖ ៩%
ប្រភព៖ ប្រទេស កម្ពុជា

## ចំនួនឥណទានជាមធ្យមរបស់ ប្រាសាក់ ក្នុងមួយគ្រួសារ ទៅតាមស្រុកនីមួយៗ



# ធនាគារ អេស៊ីលីដា

ធនាគារ អេស៊ីលីដា

**ACLEDA FINANCIAL TRUST & STAFF ASSOCIATION**
ភាគហ៊ុន៖ ៥១,០០%
ប្រភពដើម៖ ប្រទេសកម្ពុជា

**SUMITOMO MITSUI BANKING CORPORATION**
ភាគហ៊ុន៖ ១៨,២៥%
ប្រភព៖ ប្រទេសជប៉ុន

**COMPAGNIE FINANCIERE DE LA BRED**
ភាគហ៊ុន៖ ១២,២៥%
ប្រភព៖ ប្រទេស បារាំង

**ORIX CORPORATION**
ភាគហ៊ុន៖ ១២,២៥%
ប្រភព៖ ប្រទេស ជប៉ុន

**TRIODOS INVESTMENT MANAGEMENT**
ភាគហ៊ុន៖ ៦,២៥%
ប្រភព៖ ប្រទេស ហូឡង់

## ចំនួនឥណទានជាមធ្យមរបស់ អេស៊ីលីដា ក្នុងមួយគ្រួសារ ទៅតាមស្រុកនីមួយៗ



# ធនាគារ ស្ថាបនា

SATHAPANA BANK

MARUHAN INVESTMENT ASIA

Shares: 100%

Origin: Japan

## ចំនួនឥណទានជាមធ្យមរបស់ ស្ថាបនា ក្នុងមួយគ្រួសារ ទៅតាមស្រុកនីមួយៗ



# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត**

- **ADVANS GROUP & LFP**
  ភាគហ៊ុន៖ ៥៦,៨៤%
  - EUROPEAN INVESTMENT BANK (EIB)
    ភាគហ៊ុន៖ ២០,៩៤%, ប្រភពដើម៖ សហភាពអឺរ៉ុប (របស់រដ្ឋ)
  - CDC GROUP
    ភាគហ៊ុន៖ ១៦,៤៥%, ប្រភពដើម៖ ចក្រភពអង់គ្លេស (របស់រដ្ឋ)
  - NETHERLANDS DEVELOPMENT FINANCE (FMO)
    ភាគហ៊ុន៖ ១៦,៤៥%, ប្រភពដើម៖ ប្រទេសហូឡង់ (របស់រដ្ឋ)
  - INTERNATIONAL FINANCE CORPORATION (IFC)
    ភាគហ៊ុន៖ ១៤,៥១%, ប្រភពដើម៖ ធនាគារពិភពលោក (របស់រដ្ឋ)
  - KFW
    ភាគហ៊ុន៖ ១៤,២០%, ប្រភពដើម៖ ប្រទេសអាល្លឺម៉ង់
  - AGENCE FRANCAISE DE DEVELOPMENT (AFD)
    ភាគហ៊ុន៖ ១០,៩៩%, ប្រភពដើម៖ ប្រទេសបារាំង (របស់រដ្ឋ)
  - ADVANS INVEST
    ភាគហ៊ុន៖ ៦,៤៥%
- **NETHERLANDS DEV. FINANCE (FMO)**
  ភាគហ៊ុន៖ ១៩,៩៩%
  ប្រភពដើម៖ ប្រទេសហូឡង់ (របស់រដ្ឋ)
- **INTERNATIONAL FINANCE CORPORATION (IFC)**
  ភាគហ៊ុន៖ ១៩,៩៩%
  ប្រភពដើម៖ ធនាគារពិភពលោក (របស់រដ្ឋ)
- **BOTTA (AMRET EMPLOYEES)**
  ភាគហ៊ុន៖ ៣,១៧%
  ប្រភពដើម៖ ប្រទេសកម្ពុជា

## ចំនួនឥណទានជាមធ្យមរបស់ អម្រឹត ក្នុងមួយគ្រួសារ ទៅតាមស្រុកនីមួយៗ



# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត**

BANK OF AYUDHYA
(KRUNGSRI)
ភាគហ៊ុន ៖ ១០០%
ប្រភពដើម៖ ប្រទេសថៃ

## ចំនួនឥណទានជាមធ្យមរបស់ ហត្ថាកសិករ ក្នុងមួយគ្រួសារ ទៅតាមស្រុកនីមួយៗ





# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី កម្ពុជា

(អតីតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ ភូមិ)

**អិលអូអិលស៊ី កម្ពុជា**

LANKA ORIX LEASING COMPANY PLC (LOLC)
ភាគហ៊ុន៖ ៩៦,៩៧%
ប្រភពដើម៖ ប្រទេស ស្រីលង្កា

TPC-ESOS (LOLC (CAMB.) EMPLOYEES
ភាគហ៊ុន៖ ៣,០៣%
ប្រភពដើម៖ ប្រទេស កម្ពុជា

ចំនួនឥណទានជាមធ្យមរបស់ អិលអូអិលស៊ី កម្ពុជា ក្នុងមួយគ្រួសារ ទៅតាមស្រុកនីមួយៗ





# អង្គរ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា (អេអឹមខេ)

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេអឹមខេ**

**SHANGHAI COMMERCIAL & SAVINGS BANK (SCSB)**

ភាគហ៊ុន៖ ៨០,០១%

ប្រភពដើម៖ ប្រទេស ចិនតៃវ៉ាន់

**AGORA MICROFINANCE**

ភាគហ៊ុន៖ គ្មានតួរលេខ

ប្រភពដើម៖ ប្រទេស ហូឡង់

**AMK STAFF ASSOCIATION (AMK-SA)**

ភាគហ៊ុន៖ គ្មានតួរលេខ

ប្រភពដើម៖ ប្រទេស កម្ពុជា

**ចំនួនឥណទានជាមធ្យមរបស់ អេអឹមខេ ក្នុងមួយគ្រួសារ ទៅតាមស្រុកនីមួយៗ**



# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រេឌីត

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
ក្រេឌីត

PHILIPCAPITAL
GROUP

ភាគហ៊ុន៖ ១០០%

ប្រភពដើម៖ ប្រទេស សិង្ហបុរី

## ចំនួនឥណទានជាមធ្យមរបស់ក្រេឌីត ក្នុងមួយគ្រួសារ ទៅតាមស្រុកនីមួយៗ



# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ី ហ្វាយណាន់

(អតីតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់)

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដាប់ប៊ែលយូប៊ីហ្វាយណាន់**

WOORI BANK GROUP

ភាគហ៊ុន៖ ១០០%

ប្រភពដើម៖ ប្រទេសកូរ៉េខាងត្បូង

ចំនួនឥណទានជាមធ្យមរបស់ ដាប់ប៊ែលយូប៊ី ហ្វាយណាន់ ក្នុងមួយគ្រួសារ ទៅតាមស្រុកនីមួយៗ



www.licadho-cambodia.org

www.teangtnaut.org